មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# ផលប៉ះពាល់ផ្នែកច្បាប់ទៅលើសេរីភាពខាងការបញ្ចេញមតិក្នុងយុគសម័យឌីជីថល

ខែវិច្ឆិកា ឆ្នាំ២០២៥



## មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (" ម.ស.ម.ក ") គឺជាអង្គការមិនមែនរដ្ឋាភិបាល មិនចូលបក្សសម្ព័ន្ធ ឯករាជ្យ និងធ្វើការលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ ម.ស.ម.ក មានចក្ខុវិស័យចង់ឱ្យប្រទេសកម្ពុជាមានសុខសន្តិភាព ដែលប្រជាពលរដ្ឋទាំងអស់អាចអនុវត្តសិទ្ធិមនុស្សជាមូលដ្ឋានដែលពួកគេមានសិទ្ធិទទួលបាន ប្រជាពលរដ្ឋទាំងអស់គោរពនីតិរដ្ឋដោយគ្មាននិទណ្ឌភាព ប្រជាពលរដ្ឋទាំងអស់ទទួលបានការគោរពស្មើភាពគ្នាដោយគ្មានការរើសអើង ប្រជាពលរដ្ឋទាំងអស់ទទួលបានការពង្រឹងភាពអង់អាចក្លាហាន ដើម្បីចូលរួមពេញលេញនៅក្នុងដំណើរការប្រជាធិបតេយ្យ ហើយប្រជាពលរដ្ឋទាំងអស់ទទួលបាននូវអត្ថប្រយោជន៍ពីការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាប្រកបដោយចីរភាព។ ស្លាកសញ្ញារបស់ ម.ស.ម.ក មានរូបសត្វស្លាបពណ៌សកំពុងហើរចេញពីរង្វង់មូលពណ៌ផ្ទៃមេឃដែលមានន័យថាជាការទាមទារសេរីភាពនៅកម្ពុជា។ សម្រាប់ព័ត៌មានបន្ថែមសូមចូលទៅកាន់គេហទំព័រ www.cchrcambodia.org

## អំពីឯកសារវិភាគផ្នែកច្បាប់នេះ

ឯកសារវិភាគផ្នែកច្បាប់នេះគឺជាលទ្ធផលនៃគម្រោងគាំទ្រប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងសេរីភាពមូលដ្ឋាននៅប្រទេសកម្ពុជា។ គម្រោងនេះបានចាប់ផ្ដើមអនុវត្តដំបូងនៅក្នុងខែកញ្ញា ឆ្នាំ២០២០ ក្នុងគោលបំណងពង្រីកលំហសេរីភាពខាងការបញ្ចេញមតិ និងបរិយាកាសពហុនិយមនិងឯករាជ្យសម្រាប់ប្រព័ន្ធផ្សព្វផ្សាយដែលសេរី និងដើម្បីបង្កើនឱកាសសម្រាប់ប្រជាពលរដ្ឋក្នុងការចូលរួមនៅក្នុងដំណើរការប្រជាធិបតេយ្យ និងធ្វើការសម្រេចចិត្តដោយការទទួលព័ត៌មានពេញលេញ។

ឯកសារវិភាគផ្នែកច្បាប់នេះផ្ដល់នូវការវាយតម្លៃថ្មីចុងក្រោយទៅលើច្បាប់ និងក្របខ័ណ្ឌច្បាប់ជាធរមាន និងសេចក្ដីព្រាងច្បាប់ដែលមានឬអាចមានផលប៉ះពាល់ដល់សេរីភាពខាងការបញ្ចេញមតិក្នុងយុគសម័យឌីជីថល។ ឯកសារនេះវិភាគទៅលើខ្លឹមសារ និងវិសាលភាពនៃច្បាប់ និងក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធព្រមទាំងវិសាលភាពដែលច្បាប់ ទាំងនោះអនុលោមតាម ឬផ្ទុយនឹងច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ពាក់ព័ន្ធនឹងសេរីភាពខាងការបញ្ចេញមតិ ការទទួលព័ត៌មាន និងសិទ្ធិឯកជនភាព។ គម្រោងនេះក៏បានរៀបចំចងក្រងរបាយការណ៍ប្រចាំឆ្នាំចំនួនបួន ដែលបានចេញផ្សាយនៅក្នុងខែមេសា ឆ្នាំ២០២២ ខែវិច្ឆិកា ឆ្នាំ២០២២ ខែវិច្ឆិកា ឆ្នាំ២០២៣ និងខែវិច្ឆិកា ឆ្នាំ២០២៤ ផងដែរ។របាយការណ៍ទាំងអស់នេះអាចរកបាននៅលើគេហទំព័ររបស់ម.ស.ម.ក៖https://www.cchrcambodia.org/en/publications/general-reports។

# សំណួរ និងមតិចូលរួម

ប្រសិនបើលោកអ្នកមានចម្ងល់ ឬចង់ផ្តល់មតិចូលរួមលើរបាយការណ៍នេះ សូមផ្ញើអ៊ីមែលមកកាន់ ម.ស.ម.ក តាមរយៈអាសយដ្ឋាន info@cchrcambodia.org។ ឯកសារវិភាគរួមទាំងឯកសារបោះពុម្ពផ្សាយផ្សេងៗរបស់ ម.ស.ម.ក មានដាក់នៅលើគេហទំព័ររបស់ ម.ស.ម.ក www.cchrcambodia.org ឬនៅលើគេហទំព័រទំព័រអំពីសិទ្ធិមនុស្សកម្ពុជា ដែលឈ្មោះពានរង្វាន់ www.sithi.org ។

ព័ត៌មានបន្ថែម សូមទាក់ទងមកកាន់ ម.ស.ម.ក តាមរយៈអាសយដ្ឋាន៖ ផ្ទះលេខ៧៩៨ ផ្លូវលេខ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរសព្ទ៖ +៨៥៥ (០) ២៣ ៧២៦ ៩០១។

# មាតិកា


វិសាលភាព និងវិធីសាស្រ្ត ១

ខ្លឹមសារសង្ខេប ២

សេចក្តីផ្តើម ៤

I. ទិដ្ឋភាពទូទៅនៃសិទ្ធិសេរីភាពខាងការបញ្ចេញមតិ ៦

II. ក្របខ័ណ្ឌច្បាប់ និងច្បាប់ជាធរមានដែលប៉ះពាល់លើការអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិតាមអនឡាញ ១០

ក. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា
ខ. ច្បាប់ស្តីពីរបបសារព័ត៌មាន
គ. ច្បាប់ស្តីពីទូរគមនាគមន៍ និងប្រកាសស្តីពីការគ្រប់គ្រងការផ្សព្វផ្សាយតាម គេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម
ឃ. ធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន និងបណ្ណសម្គាល់អ្នកសារព័ត៌មាន
ង. អនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ

III.សេចក្តីព្រាងច្បាប់ និងគោលនយោបាយដែលប៉ះពាល់ដល់ការទទួលបានសិទ្ធិសេរីភាពខាងការបញ្ចេញមតិ សិទ្ធិទទួលព័ត៌មាន និងឯកជនភាពតាមអ៊ីនធឺណិត ២៣

ក. សេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យា
ខ. សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន
គ. សេចក្តីព្រាងច្បាប់ស្តីពីសន្តិសុខសាយប័រ
ឃ. សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារទិន្នន័យបុគ្គល

សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ៣៥

## វិសាលភាព

ការវិភាគផ្នែកច្បាប់នេះផ្តោតលើច្បាប់ និងបទដ្ឋានថ្មីៗពាក់ព័ន្ធនឹងសេរីភាពខាងការបញ្ចេញមតិតាមប្រព័ន្ធឌីជីថលនៅកម្ពុជា ដែលមានចែងនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ហើយធ្វើការប្រៀបធៀបច្បាប់ និងក្របខ័ណ្ឌច្បាប់កម្ពុជាទៅនឹងច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ដែលរួមបញ្ចូលទាំងភាពស៊ីសង្វាក់ និងភាពផ្ទុយគ្នា។ ការវិភាគនេះ ក៏ផ្តល់អនុសាសន៍មួយចំនួនដើម្បីធានាបាននូវភាពស៊ីសង្វាក់គ្នានៃច្បាប់ពាក់ព័ន្ធជាមួយច្បាប់សិទ្ធិមនុស្សអន្តរជាតិ និង បទដ្ឋានសិទ្ធិមនុស្សផងដែរ ។

## វិធីសាស្ត្រ

ការវិភាគនេះបានធ្វើឡើងដោយផ្អែកលើការពិនិត្យមើលឯកសារ ការស្រាវជ្រាវបែបប្រៀបធៀប និងការវិភាគច្បាប់កម្ពុជា និងច្បាប់អន្តរជាតិដែលពាក់ព័ន្ធនឹងសេរីភាពខាងការបញ្ចេញមតិក្នុងយុគសម័យឌីជីថល ដោយផ្តោតជាពិសេសលើបញ្ហាប្រឈមដែលកំពុងកើតឡើងពាក់ព័ន្ធនឹងការអនុវត្តច្បាប់ ភាពមិនច្បាស់លាស់នៃច្បាប់ និងភាពមិនស៊ីសង្វាក់គ្នារវាងច្បាប់កម្ពុជា និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

# ខ្លឹមសារសង្ខេប


ការវិភាគផ្នែកច្បាប់នេះ វាយតម្លៃលើវិសាលភាពច្បាប់ និងបទប្បញ្ញត្តិច្បាប់មានស្រាប់ ដែលត្រូវបានប្រើប្រាស់ដើម្បីរឹតត្បិតសេរីភាពខាងការបញ្ចេញមតិនៅក្នុងយុគសម័យឌីជីថល ហើយការវាយតម្លៃដូចគ្នានេះក៏ធ្វើទៅលើសេចក្តីព្រាងច្បាប់មួយចំនួនដែលអាចរឹតត្បិតក្នុងវិសាលភាពផ្សេងៗគ្នា។ រូបភាពដែលទទួលបានពីការវិភាគនេះ បង្ហាញថាសេចក្តីព្រាងច្បាប់ដែលកំពុងត្រូវបានធ្វើការពិភាក្សាអាចធ្វើឱ្យមានបរិយាកាសរឹតត្បិតកាន់តែខ្លាំងឡើងទៅលើសេរីភាខាងការញ្ចេញមតិ។

ការវាយតម្លៃទៅលើបញ្ញត្តិច្បាប់ និងច្បាប់ជាធរមាន គូសបញ្ជាក់ពីការពិតដែលថា ទាំងការបង្កើត និងការអនុវត្តបញ្ញត្តិច្បាប់ និងច្បាប់ទាំងនេះ ធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិ។ មាត្រាមួយចំនួននៃក្រមព្រហ្មទណ្ឌ ជាពិសេសមាត្រា ៣០៥ (បទបរិហារកេរ្តិ៍ជាសាធារណៈ) មាត្រា៤៩៤ និងមាត្រា ៤៩៥ (បទញុះញង់) មាត្រា ៣០៧ (បទជេរប្រមាថជាសាធារណៈ) មាត្រា ៥២៣ (បទធ្វើឱ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ) និងមាត្រា៥០២ (បទប្រមាថ) គឺឧទាហរណ៍មួយចំនួនដែលភាគច្រើនមិនបំពេញតាមលក្ខខណ្ឌនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិនោះទេ។ ច្បាប់ស្តីពីរបបសារព័ត៌មានឆ្នាំ ១៩៩៥ មានលក្ខណៈរឹតត្បិតជាជាងសម្រួល ឬបង្កើតលក្ខខណ្ឌអំណោយផលសម្រាប់ការអនុវត្តសេរីភាពរបស់ប្រព័ន្ធផ្សព្វផ្សាយដែលជាចេតនាទូទៅនៃច្បាប់បែបនេះ។ ច្បាប់នេះមិនត្រឹមតែដាក់កំហិតលើខ្លឹមសារប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបើកផ្លូវយ៉ាងទូលាយក្នុងការបកស្រាយ ដោយសារតែប្រើពាក្យពេចន៍មិនច្បាស់លាស់។ ច្បាប់ស្តីពីទូរគមនាគមន៍ (ឆ្នាំ២០១៥) និងប្រកាសអន្តរក្រសួងលេខ ១៧០ ស្តីពី ការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម ដែលដំណើរការតាមប្រព័ន្ធអ៊ីនធឺណិត នៅព្រះរាជាណាក្រកម្ពុជា (ឆ្នាំ២០១៨) ផ្តល់អំណាចយ៉ាងទូលំទូលាយដោយកំណត់វិសាលភាពមិនសមាមាត្រ និងមិនច្បាស់លាស់ក្នុងការបង្កើតបញ្ញត្តិជាច្រើននៃច្បាប់នោះ។ ស្ថានភាពសម្រាប់សេរីភាពប្រព័ន្ធផ្សព្វផ្សាយ ដែលបានចុះខ្សោយតាមរយៈច្បាប់សារព័ត៌មាន ត្រូវបានធ្វើឱ្យកាន់តែងាយរងគ្រោះបន្ថែមទៀតតាមរយៈការអនុម័តលក្ខខណ្ឌសម្រាប់វិជ្ជាជីវៈសារព័ត៌មាន និងប័ណ្ណសំគាល់អ្នកសារព័ត៌មាន។ ការឃ្លាំមើល ការស្ទាក់ចាប់ និងការត្រួតពិនិត្យសកម្មភាពលើប្រព័ន្ធអ៊ីនធឺណិតត្រូវបានចែងនៅក្នុងអនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិដែលត្រូវបានពន្យារពេលអនុវត្ត ទោះបីជាត្រូវបានប្រកាឱ្យអនុវត្តចាប់ពីខែកុម្ភៈ ឆ្នាំ២០២២ មកក្តី ។

ការវិភាគលើសេចក្តីព្រាងច្បាប់នេះ ក៏បានបង្ហាញពីក្តីបារម្ភស្រដៀងគ្នានេះពាក់ព័ន្ធនឹងកង្វះភាពជាក់លាក់នៅក្នុងមាត្រាផ្សេងៗ ដែលធ្វើឱ្យច្បាប់នេះងាយនឹងត្រូវបានអនុវត្តដើម្បីបម្រើផលប្រយោជន៍ផ្ទាល់ខ្លួន ឬក្នុងគោលបំណងនយោបាយ។ សេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យា បង្កឱ្យមានការព្រួយបារម្ភជាពិសេសដោយហេតុថាសេចក្តីព្រាងច្បាប់នេះមានរួមបញ្ចូលនូវការផ្តន្ទាទោសកាន់តែធ្ងន់ធ្ងរ ដូចជាការដាក់ពន្ធនាគារសម្រាប់បទល្មើសដែលមានកំណត់រួចហើយនៅក្នុងក្រមព្រហ្មទណ្ឌ ប៉ុន្តែមិនមានកំណត់ទោសទណ្ឌបែបនេះ។ ហេតុដូច្នេះ ការណ៍នេះអាចបង្ហាញពីការប៉ុនប៉ងកំណត់សេរីភាពខាងការបញ្ចេញមតិ ជាបទល្មើសព្រហ្មទណ្ឌកាន់តែធ្ងន់ធ្ងរជាងកម្រិតដែលមានកំណត់នៅក្នុងក្រមព្រហ្ម-ទណ្ឌរួចហើយ សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន ទោះបីជាដំណើរការនៃការរៀបចំសេចក្តីព្រាងច្បាប់នេះមានការពិគ្រោះយោបល់ក៏ដោយ ក៏នៅតែមានបញ្ញត្តិលក្ខណៈទូទៅមួយចំនួនដែលបង្កឱ្យមានឧបសគ្គគួរឱ្យកត់សម្គាល់ក្នុងការទទួលបានព័ត៌មានផងដែរ។ អំណាចគួរឱ្យកត់សម្គាល់ពាក់ព័ន្ធនឹងអភិបាលកិច្ចសន្តិសុខឌីជីថល ត្រូវបានប្រគល់ជូនស្ថាប័នប្រតិបត្តិមួយ ឈ្មោះថាគណៈកម្មាធិការសន្តិសុខឌីជីថល ក៏ដូចជាអធិការកិច្ចសន្តិសុខសាយប័រ ដែលបង្កើតការព្រួយបារម្ភថា អាចនាំឱ្យមានការគ្រប់ដណ្តប់ហួសហេតុ ។

ទោះបីជាមានការព្រួយបារម្ភទាំងនេះក៏ដោយ ដោយសារតែច្បាប់នានាដែលបានលើកឡើងខាងលើ ស្ថិតក្នុងដំណាក់កាលរៀបចំសេចក្តីព្រាងនៅឡើយ យើងនៅមានឱកាសធ្វើការកែសម្រួលសេចក្តីព្រាងច្បាប់ ទាំងនោះព្រមទាំងធានាថា ច្បាប់ទាំងនោះអនុលោមតាមកាតព្វកិច្ចរបស់ប្រទេសកម្ពុជាក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ ដូចគ្នានេះដែរ ចាប់តាំងពីខែសីហា ឆ្នាំ២០២៤ នៅពេលដែលរាជរដ្ឋាភិបាលកម្ពុជាបានពិនិត្យមើលក្រមព្រហ្មទណ្ឌឡើងវិញ ផ្តល់ឱកាសក្នុងការធ្វើកំណែទម្រង់បញ្ញត្តិដែលបានរៀបរាប់ខាងលើដើម្បីធ្វើវិសោធនកម្មឱ្យស្របតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

# សេចក្ដីផ្ដើម

ដូចគ្នាទៅនឹងបណ្ដាប្រទេសនានានៅទូទាំងពិភពលោកដែរ បច្ចេកវិទ្យាឌីជីថលនៅកម្ពុជាបានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើរបៀបអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិ។ ដោយសារតែបច្ចេកវិទ្យាឌីជីថលបានរីករាលដាលនៅក្នុងទិដ្ឋភាពជាច្រើននៃជីវិតប្រចាំថ្ងៃរបស់យើង ជាពិសេសរបៀបប្រាស្រ័យទាក់ទងទៅវិញទៅមករបស់យើងនិងនៅក្នុងសង្គមកាន់តែទូលំទូលាយ សិទ្ធិនេះត្រូវបានអះអាងថាបានអនុវត្តច្រើនបំផុតនៅលើប្រព័ន្ធអ៊ីនធឺណិត ដែលស្មើតែស្មើគ្នានឹងការអនុវត្តនៅក្រៅបណ្ដាញអ៊ីនធឺណិតដែរ។

គិតត្រឹមដើមឆ្នាំ២០២៥ មានអ្នកប្រើប្រាស់បណ្ដាញសង្គមចំនួន ១២,៩ លាននាក់នៅក្នុងប្រទេសកម្ពុជាដែលស្មើនឹង ៧២,៤ ភាគរយនៃចំនួនប្រជាពលរដ្ឋសរុប។[1] នៅពេលដែលបច្ចេកវិទ្យាឌីជីថល ដូចជាបណ្ដាញសង្គម កម្មវិធីផ្ញើសារ និងប្លុកចាប់ផ្ដើមមានវត្តមានជាលើកដំបូងនៅក្នុងប្រទេសកម្ពុជា បុគ្គលម្នាក់ៗអាចបញ្ចេញមតិផ្ទាល់ខ្លួនតាមប្រព័ន្ធអ៊ីនធឺណិតដោយមានការត្រួតពិនិត្យតិចតួច និងដោយគ្មានការភ័យខ្លាចចំពោះការឃ្លាំមើល ឬការត្រួតពិនិត្យរបស់រដ្ឋាភិបាលនោះទេ។ វេទិកាឌីជីថលថ្មីទាំងនេះបានផ្ដល់ជម្រើសជំនួសនានាសម្រាប់សាធារណជនចូលរួមជាមួយសង្គមដ៏ទូលំទូលាយ និងបញ្ចេញមតិរបស់ខ្លួនដែលក្រោយមកបានពង្រីកលំហសម្រាប់សេរីភាពខាងការបញ្ចេញមតិ។ វេទិកាឌីជីថលទាំងនេះក៏អនុញ្ញាតឱ្យសាធារណជនបញ្ចេញមតិចំពោះគោលនយោបាយ និងការសម្រេចចិត្តរបស់រដ្ឋាភិបាលដែលពេលខ្លះមានផលវិជ្ជមាន។ ឧទាហរណ៍មួយក្នុងចំណោមនោះ គឺការតវ៉ាជាសាធារណៈនៅឆ្នាំ២០២២ប្រឆាំងនឹងការផ្ដល់ដីសម្បទានដី ភ្នំ<u>តាម៉ៅ</u> របស់រាជរដ្ឋាភិបាលកម្ពុជាទៅឱ្យក្រុមហ៊ុនឯកជនមួយ។ នៅទីបំផុតរាជរដ្ឋាភិបាលបានលុបចោលការសម្រេចចិត្តការអនុវត្តការផ្ដល់ដីសម្បទាននោះ ដោយលើកឡើងថាប្រតិកម្មរបស់សាធារណជន គឺជាកត្តាមួយនៅក្នុងការសម្រេចចិត្ត ។[2]

គួរឱ្យសោកស្ដាយ ហេតុការណ៍បែបនេះបានក្លាយជាករណីមិនទូទៅនោះទេ ដោយហេតុថាការអនុវត្តពេញលេញនូវសេរីភាពខាងការបញ្ចេញមតិតាមប្រព័ន្ធអ៊ីនធឺណិតមិនមានរយៈពេលយូរនោះទេ។ ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ រដ្ឋាភិបាលបានបង្កើតច្បាប់ និងគោលនយោបាយថ្មីៗកាន់តែច្រើនឡើងដើម្បីឆ្លើយតបទៅនឹងការកើនឡើងនៃអត្រាប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។ ខណៈពេលដែលការបង្កើតច្បាប់ និងគោលនយោបាយមានសារៈសំខាន់ខ្លាំងក្នុងការសម្របខ្លួនទៅនឹងតម្រូវការដែលកំពុងតែប្រែប្រួលរបស់សង្គមកម្ពុជា ម.ស.ម.ក មានការព្រួយបារម្ភចំពោះខ្លឹមសារនៃការវិវឌ្ឍមួយចំនួនទាំងនេះ និងរបៀបដែលខ្លឹមសារទាំងនេះអាចត្រូវបានប្រើដើម្បីរឹតត្បិតសិទ្ធិសេរីភាពខាងការបញ្ចេញមតិបន្ថែមទៀត។ ខ្លឹមសារទាំងនេះ ក៏ជាការបន្ថែមទៅក្នុងឧបករណ៍នីតិបញ្ញត្តិរបស់រាជរដ្ឋាភិបាលកម្ពុជាផងដែរ ដោយសារច្បាប់ និងបទប្បញ្ញត្តិមួយចំនួននៃក្រមព្រហ្មទណ្ឌ ត្រូវបានប្រើប្រាស់ដើម្បីរឹតត្បិតសិទ្ធិនេះ និងបានផ្ដន្ទាទោសអ្នកដែលប្រើប្រាស់សិទ្ធិដើម្បីបញ្ចេញមតិផ្ទុយ។ ជាលទ្ធផល សាធារណជនមានការកំហិតសិទ្ធិខ្លួនឯងកាន់តែច្រើនចំពោះការបញ្ចេញមតិនៅលើបណ្ដាញសង្គម។ ឧទាហរណ៍ នៅឆ្នាំ២០២១ កសិករម្នាក់នៅខេត្តបាត់ដំបងបានធ្វើការ <u>បញ្ចេញមតិ</u> នៅលើប្រព័ន្ធបណ្ដាញសង្គមចំពោះសំណើរបស់អតីតនាយករដ្ឋមន្ត្រីដើម្បីទិញផ្លែតាង៉ែនពីកសិករដែលរបងផលប៉ះពាល់ដោយសារតែបញ្ហានាំចេញត្រូវបានចាប់ខ្លួន និងផ្ដន្ទាទោសពីបទញុះញង់។[3]

---

[1] Datareportal ឌីជីថល ឆ្នាំ ២០២៥៖ កម្ពុជា (ចូលមើលថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០២៥) រកមើលបាននៅ <u>ឌីជីថល ឆ្នាំ២០២៥៖ កម្ពុជា — Data Reportal – ព័ត៌មានឌីជីថលសកល</u>

[2] ភ្នំពេញប៉ុស្តិ៍ <u>នាយករដ្ឋមន្ត្រីសង្គ្រោះព្រៃភ្នំតាម៉ៅពីការកាប់បំផ្លាញ</u> (ថ្ងៃទី ៧ ខែសីហា ឆ្នាំ២០២២)។

[3] VOA, តុលាការខេត្តបាត់ដំបងកាត់ទោសកសិករដាំផ្លែមានឱ្យជាប់ពន្ធធនាគារ  (ថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០២១)។

ក្រៅពីនេះវេទិកាឌីជីថលត្រូវបានអ្នកជទៃប្រើប្រាស់កាន់តែច្រើនឡើងដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ជាពិសេសតាម ប្រតិបត្តិការឆបោកតាមអ៊ីនធឺណិត នៅទីតាំងឆបោកយ៉ាងតិច ៥៣ កន្លែងនៅទូទាំងប្រទេស។ ជាផ្នែកមួយនៃប្រតិបត្តិការបែបនេះ ការរាយការណ៍ និង ការស៊ើបអង្កេត យ៉ាងហ្មត់ចត់បានបង្ហាញថា អ្នកដែលត្រូវបាន ជួញដូរមកកម្ពុជា ពេលមកដល់ត្រូវបានគេនាំទៅកាន់កន្លែងឆបោក និងបង្ខំឱ្យចូលរួមក្នុងការឆបោកតាមអ៊ីនធឺណិត ហើយនឹងត្រូវរងការរំលោភបំពានផ្លូវចិត្ត និងរាងកាយប្រសិនបើពួកគេជំទាស់។[4] ចាប់តាំងពីដើមឆ្នាំ ២០២៥ រាជរដ្ឋាភិបាលបានចាប់ខ្លួនមនុស្សរាប់រយនាក់ ដែលជាផ្នែកមួយនៃ ការបង្ក្រាបមជ្ឈមណ្ឌលឆបោក ទោះជាយ៉ាងនេះក្តីរបាយការណ៍បានបង្ហាញថា ជនរងគ្រោះ គឺជាគោលដៅក្នុងការចាប់ខ្លួនមិនមែនអ្នកដែលនៅពីក្រោយប្រតិបត្តិការនោះទេ។ ទោះបីជាមានតម្រូវការជាក់ស្តែងក្នុងការដោះស្រាយបញ្ហានេះឱ្យបានឆាប់រហ័ស និងគ្រប់ជ្រុងជ្រោយក៏ដោយ ច្បាប់ដែលមានបំណងសម្រាប់កិច្ចការនេះត្រូវតែគោរពតាមសិទ្ធិមនុស្ស និងមិនត្រូវអនុវត្តតាមអំពើចិត្តឡើយ។ ត្រូវមានតុល្យភាពរវាងការធានាសន្តិសុខ និងសេរីភាពខាងការបញ្ចេញមតិ ការទទួលព័ត៌មាន និងឯកជនភាព។

ស្ថិតនៅក្នុងបរិបទនេះហើយ ទើបធ្វើឱ្យ ម.ស.ម.ក បង្កើតការវិភាគផ្នែកច្បាប់នេះឡើង។ ការវិភាគនេះមានគោលបំណង ផ្តល់នូវទិដ្ឋភាពទូទៅនៃច្បាប់ជាធរមាន និងសេចក្តីព្រាងច្បាប់ទាក់ទងនឹងសិទ្ធិសេរីភាពខាងកាបញ្ចេញមតិ ក្នុងគោលបំណងផ្តល់ផលប្រយោជន៍ដល់សង្គមស៊ីវិល អ្នកសារព័ត៌មាន និងសាធារណជន ដើម្បីឱ្យពួកគេអាចប្រើប្រាស់លំហឌីជីថលបច្ចុប្បន្នបានកាន់តែប្រសើរឡើងក្នុងការអនុវត្ត ទាមទារ និងការការពារសិទ្ធិរបស់ពួកគេ និងសិទ្ធិរបស់អ្នកដទៃ។ ឯកសារវិភាគនេះក៏មានគោលបំណងទុកជាប្រយោជន៍ដល់អ្នកបង្កើតគោលនយោបាយ និងភាគីពាក់ព័ន្ធ ដើម្បីឆ្លុះបញ្ចាំងពីក្តីបារម្ភទាក់ទងនឹងសេចក្តីព្រាងច្បាប់បច្ចុប្បន្ន និងផលប៉ះពាល់ដែលអាចកើតមាន ទៅលើការទទួលបានសិទ្ធិសេរីភាពខាងការបញ្ចេញមតិក្នុងយុគសម័យឌីជីថលនេះ។

[4] Australian Aid, ការជួញដូរមនុស្ស និងពលកម្មដោយបង្ខំនៅក្នុងឧស្សាហកម្មឆបោកតាមអ៊ីនធឺណិតរបស់កម្ពុជា (ថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០២៤)។

# ផ្នែកទី I

# ទិដ្ឋភាពទូទៅនៃសិទ្ធិសេរីភាពខាងការបញ្ចេញមតិ



សេរីភាពខាងការបញ្ចេញមតិ គឺជាសេរីភាពជាមូលដ្ឋានដែលធានាថាប្រជាពលរដ្ឋអាចពិភាក្សា ផ្លាស់ប្ដូរមតិយោបល់ និងជជែកវែកញែកអំពីគំនិតគ្រប់ប្រភេទ ក៏ដូចជាការទទួលព័ត៌មាន និងចែករំលែកព័ត៌មានទាំងនោះជាមួយអ្នកដទៃ ដោយមិនរងការត្រួតពិនិត្យ ឬការតបត។ សេរីភាពខាងការបញ្ចេញមតិមិនត្រឹមតែជាសិទ្ធិមនុស្សប៉ុណ្ណោះទេ ប៉ុន្តែក៏ដើរតួនាទីយ៉ាងសំខាន់ក្នុងការទទួលបានសិទ្ធិផ្សេងៗទៀតផងដែរ។ សេរីភាពខាងការបញ្ចេញមតិក៏ជាលក្ខខណ្ឌចាំបាច់សម្រាប់តម្លាភាព និងគណនេយ្យភាព ដែលជាលក្ខខណ្ឌចាំបាច់ក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស នីតិរដ្ឋ និងលទ្ធិប្រជាធិបតេយ្យ។[5]

សិទ្ធិសេរីភាពខាងការបញ្ចេញមតិត្រូវបានធានាក្រោមមាត្រា ១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ក.អ.ស.ព.ន ) ដែលកម្ពុជាបានផ្ដល់សច្ចាប័នក្នុងឆ្នាំ១៩៩២ និងមាត្រាដូចគ្នានៃសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស។ មាត្រា ១៩ (២) នៃ ក.អ.ស.ព.ន ចែងថា "មនុស្សគ្រប់រូបមានសិទ្ធិសេរីភាពខាងការបញ្ចេញមតិ ដែលសិទ្ធិនេះរួមមាន សេរីភាពស្វែងរក ទទួល និងចែករំលែកព័ត៌មាន និងគំនិតគ្រប់ប្រភេទ ដោយមិនគិតពីព្រំដែន ទាំងផ្ទាល់មាត់ ជាលាយលក្ខណ៍អក្សរ ឬបោះពុម្ព ជាទម្រង់សិល្បៈ ឬតាមរយៈប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀតតាមជម្រើសរបស់ខ្លួន"។[6]

ទោះជាយ៉ាងណាក៏ដោយ សិទ្ធិសេរីភាពខាងការបញ្ចេញមតិមិនមែនជាសិទ្ធិដាច់ខាតទេ ដូច្នេះ សិទ្ធិនេះអាចរងនូវការរឹតត្បិតមួយចំនួន ដូចដែលបានគូសបញ្ជាក់ក្នុងមាត្រា ១៩(៣)។ ដូច្នេះការរឹតត្បិតទាំងនេះត្រូវតែ៖

- ចែងដោយច្បាប់ និង
- ចាំបាច់សម្រាប់
  - ការគោរពសិទ្ធិ និងកេរ្តិ៍ឈ្មោះរបស់អ្នកដទៃ
  - ការការពារសន្តិសុខជាតិ និងសណ្ដាប់ធ្នាប់សាធារណៈ ឬសុខភាព ឬសីលធម៌សាធារណៈ។[7]

ដើម្បីវាយតម្លៃថាតើការរឹតត្បិតណាមួយត្រឹមត្រូវឬអត់ យើងត្រូវធ្វើការថ្លឹងថ្លែងបីចំណុច៖

១) តើការរឹតត្បិតនោះចែងដោយច្បាប់ដែរឬទេ?
២) តើការរឹតត្បិតនោះបម្រើគោលបំណងស្របច្បាប់ដែរឬទេ?
៣) តើការរឹតត្បិតនោះមានភាពចាំបាច់ និងសមាមាត្រ ដែរឬទេ?

ដើម្បីស្វែងយល់ឱ្យកាន់តែស៊ីជម្រៅអំពីសមាសធាតុនីមួយៗនៃការថ្លឹងថ្លែងទាំងបីចំណុចនេះដែលជាប្រយោជន៍ក្នុងការអនុវត្ត ជាក់ស្ដែង៖

[5] សេចក្ដីពន្យល់ទូទៅលេខ ៣៤ នៃមាត្រា ១៩ នៃក.អ.ស.ព.ន, គណៈកម្មាធិការសិទ្ធិមនុស្ស លើកទី ១០២ ខែកក្កដា លេខ ២១១ ទំព័រ ១។
[6] ក.អ.ស.ព.ន. មាត្រា ១៩ (កថាខណ្ឌ ២)។
[7] ក.អ.ស.ព.ន. មាត្រា ១៩ (កថាខណ្ឌ ៣)។

## ១) ចែងដោយច្បាប់

ការរឹតត្បិតត្រូវតែមានចែងនៅក្នុងច្បាប់។ យ៉ាងណាមិញ ច្បាប់ត្រូវតែបំពេញតាមការធ្វើការថ្លឹងថ្លែងនៃ "ភាពប្រាកដប្រជាផ្នែកច្បាប់" ពោលគឺ ច្បាប់នោះត្រូវតែបានបង្កើតឡើងតាមរបៀបច្បាស់លាស់ និងអាចប្រមើលមើលទុកជាមុនបាន និងមិនមានប្រតិសកម្ម ។[8] បុគ្គលម្នាក់គួរតែអាចកំណត់បានពីខ្លឹមសារនៃច្បាប់ ថាតើការបញ្ចេញមតិប្រភេទណាដែលត្រូវបានរឹតត្បិត ដើម្បីអាចឱ្យពួកគេគ្រប់គ្រងឥរិយាបថរបស់ខ្លួនបានសមស្រប។ ដូច្នេះ ច្បាប់មិនត្រូវប្រើពាក្យដែលមិនច្បាស់លាស់ ដែលអាចឱ្យមានការប្រើប្រាស់ខុស ឬអនុវត្តតាមអំពើចិត្តនោះទេ។

## ២) បម្រើដល់គោលបំណងស្របច្បាប់

ការរឹតត្បិតនីមួយៗ ត្រូវតែបម្រើដល់គោលបំណងស្របច្បាប់ណាមួយក្នុងចំណោមគោលបំណងស្របច្បាប់ដែលបានរៀបរាប់នៅក្នុងមាត្រា ១៩ (៣) អនុកថាខ័ណ្ឌ (ក) និង (ខ)។ ដូច្នេះគោលដៅតែមួយគត់ដែលអាចលើកយកមកប្រើប្រាស់ដោយស្របច្បាប់ដើម្បីរឹតត្បិតសេរីភាពខាងការបញ្ចេញមតិគឺ៖ (ក) ការគោរពសិទ្ធិ ឬកេរ្តិ៍ឈ្មោះរបស់អ្នកដទៃ និង(ខ) ការការពារសន្តិសុខជាតិ ឬសណ្តាប់ធ្នាប់សាធារណៈ ឬសុខភាព ឬសីលធម៌សាធារណៈ។ ដូច្នេះរដ្ឋមិនអាចហាមឃាត់ការចែករំលែកព័ត៌មាន ឬការបញ្ចេញមតិដោយផ្អែកលើមូលដ្ឋានដែលពួកគេបានបញ្ចេញទស្សនៈរិះគន់រដ្ឋាភិបាលនោះទេ ព្រោះការរឹតត្បិតបែបនេះមិនបម្រើដល់គោលបំណងស្របច្បាប់ណាមួយដែលមានចែងក្នុងមាត្រា ១៩ (៣)(ក) ឬ (ខ) ឡើយ ។

ទាក់ទងនឹងមាត្រា ១៩ (៣) (ក) ជារឿងសំខាន់ផងដែរក្នុងការចងចាំថា បុគ្គលសាធារណៈទាំងអស់រួមទាំងអ្នកដែលមានអំណាចជាន់ខ្ពស់ផ្នែកនយោបាយ គឺត្រូវទទួលរងការរិះគន់ និងការជំទាស់ខាងនយោបាយដោយស្របច្បាប់ ដោយសារតែមុខតំណែងរបស់ពួកគេ។[9] ស្រដៀងគ្នានេះដែរ ការរឹតត្បិតសេរីភាពខាងការបញ្ចេញមតិមិនអាចជាលេសសម្រាប់ការពាររដ្ឋាភិបាលពីភាពអាម៉ាស់ ឬការលាតត្រដាងពីកំហុសឆ្គង ឬដើម្បីលាក់បាំងព័ត៌មានអំពីដំណើរការរបស់ស្ថាប័នសាធារណៈរបស់ខ្លួនឡើយ។

ទាក់ទងនឹងមាត្រា ១៩ (៣)(ខ) សន្តិសុខជាតិ និងសណ្តាប់ធ្នាប់សាធារណៈ មិនមានន័យដូចគ្នានឹងពាក្យថាផលប្រយោជន៍ជាតិ នយោបាយ ឬរដ្ឋាភិបាលនោះទេ។[10] សណ្តាប់ធ្នាប់សាធារណៈ សំដៅលើបណ្តុំនៃច្បាប់ដែលធានាដល់ដំណើរការប្រកបដោយសន្តិភាព និងប្រសិទ្ធភាពរបស់សង្គម ចំណែកឯសន្តិសុខជាតិសំដៅទៅលើឯករាជ្យភាពនយោបាយ និង/ឬបូរណភាពទឹកដីរបស់រដ្ឋ។ គណៈកម្មាធិការសិទ្ធិមនុស្សក៏បានបញ្ជាក់យ៉ាងច្បាស់ផងដែរថាមិនត្រូវប្រើប្រាស់មាត្រា ១៩ (៣)(ខ) ស្តីពីសន្តិសុខជាតិ ដើម្បី"បង្ក្រាប ឬលាក់បាំងព័ត៌មានសាធារណៈដែលជាផលប្រយោជន៍សាធារណៈស្របច្បាប់" ឬសម្រាប់ការចោទប្រកាន់អ្នកសារព័ត៌មាន អ្នកស្រាវជ្រាវ សកម្មជនបរិស្ថានអ្នកការពារសិទ្ធិមនុស្ស ឬជនដទៃឡើយ។[11]

---

[8] Andrew Ashworth និង Lucia Zedner, Preventive Justice (សារព័ត៌មានសកលវិទ្យាល័យ Oxford ឆ្នាំ ២០១៤) ទំព័រ ១១៣-១១៤។
[9] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ សេចក្តីពន្យល់ទូទៅលេខ ៣៤, 'មាត្រា ១៩៖ សេរីភាពខាងការបញ្ចេញមតិ និងយោបល់" (ថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ ២០១១), ក.អ.ស.ព.ន. /C/GC/៣៤, កថាខណ្ឌ ៣៨ https://www2.ohchr.org/english/bodies/hrc/docs/GC34.pdf.
[10] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ, "សេចក្តីរាយការណ៍រួមរបស់អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិសេរីភាពខាងការប្រមូលផ្តុំ និងបង្កើតសមាគមដោយសន្តិវិធី និងរបាយការណ៍ពីអ្នករាយការពិសេសស្តីពីការប្រហារជីវិតក្រៅប្រព័ន្ធតុលាការ ដោយសង្ខេប និងតាមទំនើងចិត្ត ទៅលើការគ្រប់គ្រងការប្រមូលផ្តុំដោយត្រឹមត្រូវ" (ថ្ងៃទី ០៤ ខែកុម្ភៈ ឆ្នាំ២០១៦) A/HRC/៣១/៦៦ កថាខណ្ឌ ៣១ https://undocs.org/en/A/HRC/31/66.
[11] ក.អ.ស.ព.ន/C/GC/34, ទំព័រ៣០

## ៣) ភាពចាំបាច់ និងសមាមាត្រ

ប្រសិនបើសេរីភាពខាងការបញ្ចេញមតិត្រូវបានរឹតត្បិត រដ្ឋត្រូវតែអាចបង្ហាញនូវមធ្យោបាយជាក់លាក់ និងតាមករណីនីមួយៗ ថាវិធានការនេះគឺចាំបាច់ ដើម្បីកំណត់លក្ខណៈជាក់លាក់នៃការគំរាមកំហែង ដោយបង្កើតទំនាក់ទំនងដោយផ្ទាល់ និងភ្លាមៗរវាងការបញ្ចេញមតិ និងការគំរាមកំហែង។[12] វិធានការនេះ ត្រូវតែមានសមាមាត្រផងដែរ មានន័យថា ការរឹតត្បិតមិនគួរលើសពីការចាំបាច់ដាច់ខាតដើម្បីសម្រេចបាននូវគោលបំណងស្របច្បាប់នោះទេ។ រដ្ឋក៏គួរតែជ្រើសរើសវិធានការណាដែលរំខានតិចតួចបំផុតដើម្បីសម្រេចបាននូវគោលដៅនេះផងដែរ ។[13]

បរិបទ ទម្រង់ និងមធ្យោបាយនៃការផ្សព្វផ្សាយការបញ្ចេញមតិក៏ពាក់ព័ន្ធផងដែរ នៅពេលសម្រេចចិត្តថាតើការរឹតត្បិតចាំបាច់ និងមានសមាមាត្រឬអត់នោះ។ ឧទាហរណ៍ នៅក្នុងបរិបទនៃការពិភាក្សានយោបាយ តម្លៃនៃសេរីភាពខាងការបញ្ចេញមតិមានលក្ខណៈ "ខ្ពស់ជាពិសេស" ហេតុដូច្នេះហើយទើបមានការត្រួតពិនិត្យយ៉ាងដិតដល់ចំពោះវិធានការនានា ដែលដាក់កំហិតលើសេរីភាពក្នុងការបញ្ចេញមតិទាក់ទងនឹងការជជែកពិភាក្សាជាសាធារណៈទាក់ទងនឹងបុគ្គលនៅក្នុងវិស័យសាធារណៈនិងនយោបាយ។[14] គំនិត និងមតិយោបល់ដែលអាចជាការ "ប្រមាថ ធ្វើឱ្យតក់ស្លុត ឬរំខាន"[15] ក៏ត្រូវបានការពារដោយសេរីភាពខាងងការបញ្ចេញមតិផងដែរ ដោយសារទាំងនេះជាតម្រូវការសម្រាប់ពហុនិយម និងការអនុគ្រោះនៅក្នុងសង្គមប្រជាធិបតេយ្យ។[16] ដូច្នេះការរឹតត្បិតដែលអាចអនុញ្ញាតបានចំពោះសេរីភាពខាងការបញ្ចេញមតិ ប្រហែលជាមិនត្រូវបានលើកឡើងជាហេតុផលសម្រាប់ការបង្ក្រាបការតស៊ូមតិណាមួយនៃលទ្ធិប្រជាធិបតេយ្យពហុបក្ស គោលការណ៍លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សឡើយ ។[17]

---

[12] ក.អ.ស.ព.ន/C/GC/៣៤ និង ៣៥

[13] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ, Vasily Poliakov v. Belarus, សេចក្តីជូនដំណឹងលេខ ២០៣០/២០១១, UN Doc ក.អ.ស.ព.ន/C/១១១/D/២០៣០/២០១១ (ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០១៤) កថាខណ្ឌ ៨.៣ https://undocs.org/CCPR/C/111/D/2030/2011.

[14] UN Human Rights Committee, General Comment 34, 'Article 19: Freedoms of opinion and expression' (12 September 2011) UN Doc CCPR/C/GC/34, para 38,https://www2.ohchr.org/english/bodies/hrc/docs/GC34.pdf.

[15] តុលាការសិទ្ធិមនុស្សអឺរ៉ុប Handyside ទល់នឹង ចក្រភពអង់គ្លេស បណ្តឹងលេខ ៥៤៩៣/៧២ (ថ្ងៃទី ៧ ខែធ្នូ ឆ្នាំ១៩៧៦) កថា ខណ្ឌ ៤៩ https://hudoc.echr.coe.int/eng#{%22itemid%22:[%22001-57499%22]}.

[16] តុលាការសិទ្ធិមនុស្សអឺរ៉ុប Gündüz ទល់នឹង ប្រទេសទួរគី បណ្តឹងលេខ ៣៥០៧១/៩៧ (ថ្ងៃទី ០៤ ខែធ្នូ ឆ្នាំ២០០៣) កថាខណ្ឌ ៤០ និង ៥១ https://www.legal-tools.org/doc/74a144/pdf/.

[17] ក.អ.ស.ព.ន/C/GC/៣៤ និង ២៣

# ផ្នែកទី II

# ក្របខ័ណ្ឌច្បាប់ និងច្បាប់ជាធរមានដែលប៉ះពាល់ដល់ការអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិតាមអនឡាញ



សិទ្ធិសេរីភាពខាងការ បញ្ចេញមតិត្រូវបានធានាដោយមាត្រា ៤១ នៃរដ្ឋធម្មនុញ្ញដែលចែងថា៖

> ពលរដ្ឋខ្មែរមានសេរីភាព ខាងការបញ្ចេញមតិ សេរីភាពខាងព័ត៌មាន សេរីភាពក្នុងការបោះពុម្ពផ្សាយ និងសេរីភាពប្រមូលផ្តុំ។ គ្មាននរណាម្នាក់ត្រូវអនុវត្តសិទ្ធិទាំងនេះដើម្បីបំពានលើកិត្តិយសអ្នកដទៃ ឬប៉ះពាល់ដល់ទំនៀមទម្លាប់ល្អរបស់សង្គម សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខជាតិឡើយ។[18]

លើសពីនេះ មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញធានានូវការគោរពចំពោះកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់កម្ពុជា រួមទាំងកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយផងដែរ។ មាត្រា ៣១ ចែងថា៖

> ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។

ទោះបីរដ្ឋធម្មនុញ្ញកម្ពុជាការពារសេរីភាពខាងការបញ្ចេញមតិតាមរយៈបញ្ញត្តិទាំងនេះក៏ដោយ ក៏បញ្ញត្តិមួយចំនួននៃក្របខ័ណ្ឌច្បាប់ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ និងញឹកញាប់ ដើម្បីរឹតត្បិតការអនុវត្តសេរីភាពខាងការបញ្ចេញមតិ ពោលគឺក្រមព្រហ្មទណ្ឌ ច្បាប់ស្តីពីរបបសារព័ត៌មាន ច្បាប់ស្តីពីទូរគមនាគមន៍ និងប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម ដែលដំណើរការតាមប្រព័ន្ធអ៊ីនធឺណិត និងធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន។



## ក. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានក្លាយជាច្បាប់ដែលត្រូវបានយកមកប្រើប្រាស់ច្រើនបំផុតក្នុងការដាក់ទោសព្រហ្មទណ្ឌទៅលើអ្នកបញ្ចេញមតិជំទាស់ ជាពិសេសសមាជិកនៃគណបក្សនយោបាយជំទាស់ អ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស និងអ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គមកាន់តែច្រើនឡើងៗ។ ជាពិសេស មាត្រាទាំងនេះមាន៖ ៣០៥ (បទបរិហារកេរ្តិ៍ជាសាធារណៈ) ៤៩៤ និង ៤៩៥ (បទញុះញង់) ៣០៧ (បទប្រមាថជាសាធារណៈ) ៥២៣ (បទធ្វើឱ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ) និង ៥០២ (បទប្រមាថ)។ ការប្រើប្រាស់មាត្រាទាំងនេះមិនត្រឹមតែបង្កឱ្យមានបញ្ហាប៉ុណ្ណោះទេ ប៉ុន្តែខ្លឹមសារនៃមាត្រាទាំងនេះថែមទាំងមិនឆ្លុះបញ្ចាំងអំពីស្មារតីនៃមាត្រា ១៩ នៃកតិកាសញ្ញាសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយផងដែរ ដែលធ្វើឱ្យមាត្រាទាំងនេះងាយនឹងត្រូវអនុវត្តតាមទំនើងចិត្ត។ យើងគួរពិនិត្យមើលឱ្យបានស៊ីជម្រៅនូវមាត្រានីមួយៗនៃមាត្រាទាំងនេះ ដើម្បីយល់កាន់តែច្បាស់ថាតើ ការបង្កើត និងការអនុវត្តមាត្រាទាំងនេះរួមចំណែកដល់ការរឹតត្បិតសេរីភាពខាងការបញ្ចេញមតិដូចម្តេចខ្លះ៖

---

[18] រដ្ឋធម្មនុញ្ញកម្ពុជា,មាត្រា ៤១។



## មាត្រា ៣០៥ (បទបរិហារកេរ្តិ៍ជាសាធារណៈ)

ក្រមព្រហ្មទណ្ឌចែងថា "គ្រប់ការអះអាងបំផ្លើស ឬការទំលាក់កំហុសដោយអសុទ្ធចិត្តលើអំពើណាមួយ ដែលនាំឱ្យប៉ះពាល់ដល់កិត្តិយស ឬ កិត្តិស័ព្ទនៃបុគ្គល ឬនៃស្ថាប័ន គឺជាការបរិហារកេរ្តិ៍។ ត្រូវពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀលទៅ ១០.០០០.០០០ (ដប់លាន) រៀល បទបរិហារកេរ្តិ៍ដែលប្រព្រឹត្តតាមមធ្យោបាយណាមួយដូចតទៅ៖ ១-តាមសំដី ទោះជាប្រភេទណាក៏ដោយដែលបញ្ចេញ នៅទីសាធារណៈ ឬនៅក្នុងសាលប្រជុំសាធារណៈ។ ២-តាមលិខិត ឬគំនូរ ទោះជាប្រភេទណាក៏ដោយដែល ផ្សព្វផ្សាយនៅក្នុងចំណោមសាធារណជន ឬដាក់តាំងសាធារណជនមើល។ ៣-តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍សម្រាប់សាធារណជន។[19] បន្ថែមពីនេះ ទោះបីបទចោទមិនមានផ្តន្ទាទោសជាប់ពន្ធនាគារក៏ដោយ ក៏ប្រជាពលរដ្ឋខ្មែរអាចជាប់ពន្ធនាគារតាមមាត្រា ៥២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៧ ដោយសារមិនបង់ប្រាក់ផាកពិន័យ។[20] ដូចដែលបានអះអាងដោយគណៈកម្មាធិការសិទ្ធិមនុស្សថា ច្បាប់ស្តីពីបទបរិហារកេរ្តិ៍ត្រូវតែបង្កើតឡើងមិនដើម្បីបិទសេរីភាពខាងការបញ្ចេញមតិនោះទេ ហើយច្បាប់ស្តីពីបទបរិហារកេរ្តិ៍គួររួមបញ្ចូលការការពារការពិត និងខចែងពីការការពារផលប្រយោជន៍សាធារណៈដែលមាត្រា ៣០៥ នៅខ្វះ។[21] ផលជះចាំបាច់នៃវិធានការក៏មានភាពមិនច្បាស់លាស់៖ "ធ្វើឱ្យខូចកិត្តិយស ឬកេរ្តិ៍ឈ្មោះសន្តិសុខសង្គម ប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ស្ថិរភាពនយោបាយ ឬទំនៀមទម្លាប់ល្អរបស់សង្គម" មានភាពស្រពេចស្រពិលខ្លាំងចំពោះការចែងទាំងនេះ ដូច្នេះធ្វើឱ្យពិបាកយល់ថាតើ ប្រភេទឥរិយាបថអ្វីខ្លះដែលត្រូវបានដាក់ទោសព្រហ្មទណ្ឌ។ ការព្រួយបារម្ភបន្ថែមទៀតនោះ គឺការដាក់បញ្ចូលនូវពាក្យ"ស្ថាប័ន"ដែលអនុញ្ញាតឱ្យមានការដាក់ទោសព្រហ្មទណ្ឌទៅលើការរិះគន់ ឬការពិនិត្យពិច័យដោយស្របច្បាប់លើស្ថាប័នសាធារណៈ។

[19] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣០៥
[20] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ៥២៥
[21] ក.អ.ស.ព.ន/C/GC/34, ទំព័រ៤៧

## មាត្រា ៤៩៤ និងមាត្រា ៤៩៥ (បទញុះញង់ឱ្យប្រព្រឹត្តបទល្មើស)

បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ ដែលភាគច្រើនត្រូវបានយកមកប្រើប្រាស់ដើម្បីរឹតត្បិតសេរីភាពខាងការបញ្ចេញមតិ គឺមាត្រា ៤៩៤ និងមាត្រា ៤៩៥ ដែលកំណត់ថាជាបទល្មើសព្រហ្មទណ្ឌចំពោះ "អំពើញុះញង់ដោយផ្ទាល់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬប្រព្រឹត្តអំពើបង្កឱ្យមានភាពវឹកវរដល់សន្តិសុខសង្គម" ប៉ុន្តែមិនមានការបកស្រាយលម្អិត ឬនិយមន័យច្បាស់លាស់ណាមួយថាតើអំពើណាចាត់ទុកជា "ការញុះញង់" ឬ "សណ្តាប់ធ្នាប់សង្គម" នោះទេ។ ភាពមិនច្បាស់លាស់ទាំងនេះមានន័យថា វិសាលភាពដែលកំណត់អំពើដែលត្រូវបានហាមឃាត់ទាំងនោះគឺមិនមានភាពច្បាស់លាស់ ដែលនាំឱ្យមានការប្រើប្រាស់ច្បាប់នេះយ៉ាងទូលំទូលាយដើម្បីចោទប្រកាន់ជនដែលមានសំឡេងជំទាស់ និងសូម្បីតែនៅពេលពួកគេអនុវត្តសេរីភាពមូលដ្ឋានជាទូទៅក៏ដោយ។ បញ្ហាកង្វះភាពជាក់លាក់នេះក៏អាចមានន័យថា មាត្រានេះមិនបានបំពេញតាមលក្ខខណ្ឌនៃភាពជាក់លាក់ផ្នែកច្បាប់ដែលច្បាប់គួរតែមានចែងឱ្យបានច្បាស់លាស់ដើម្បីឱ្យប្រជាពលរដ្ឋអាចប្រព្រឹត្តសកម្មភាពរបស់ខ្លួនដោយអនុលោមតាមច្បាប់។ អាស្រ័យហេតុនេះ ការចោទប្រកាន់តួអង្គសង្គមស៊ីវិលណាម្នាក់ ជាពិសេស ពីបទប្រព្រឹត្ត "អំពើញុះញង់" ត្រូវបានរិះគន់ជាហូរហែរពីសំណាក់អ្នកជំនាញផ្នែកសិទ្ធិមនុស្ស។[22]

បុគ្គលដែលត្រូវបាន ចោទប្រកាន់ពីបទញុះញង់ នេះអាចត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ ខែ ដល់ ២ ឆ្នាំ និងពិន័យជាទឹកប្រាក់ចាប់ ពី ១ លានរៀល ដល់ ៤ លានរៀលទោះបីជា បទញុះញង់នោះមិនមានប្រសិទ្ធភាពក៏ដោយ។[23]

## មាត្រា៤៣៧ ស្ទួន (ប្រមាថចំពោះអង្គព្រះមហាក្សត្រ)

នៅឆ្នាំ២០១៨ ក្រមព្រហ្មទណ្ឌត្រូវបានធ្វើវិសោធនកម្មដើម្បីបញ្ចូលបទល្មើសប្រមាថអង្គព្រះមហាក្សត្រ គឺមាត្រា ៤៣៧-ស្ទួន «បទប្រមាថអង្គព្រះមហាក្សត្រ»។ មាត្រានេះហាមឃាត់ «ការប្រមាថដល់អង្គព្រះមហាក្សត្រ» ដែលត្រូវបានកំណត់ថាជា «រាល់វាចា កាយវិការ សំណេរ គំនូរ ឬវត្ថុផ្សេងៗដែលអាចប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរបស់បុគ្គល»។ បទចោទនេះត្រូវជាប់ពន្ធនាគារពីមួយឆ្នាំទៅប្រាំឆ្នាំ។ នេះគឺផ្ទុយនឹងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដែលចែងថាការខូចខាតកេរ្តិ៍ឈ្មោះមិនត្រូវផ្តន្ទាទោសតាមរយៈការជាប់ពន្ធនាគារឡើយ។[24] ចាប់តាំងពីការដាក់បញ្ចូលវិសោធនកម្មនេះមក ម.ស.ម.ក បានចងក្រងឯកសារយ៉ាងហោចណាស់ ១០ ករណីដែលពាក់ព័ន្ធនឹងបុគ្គល ១២ នាក់ដែលត្រូវបានចោទប្រកាន់ពីបទល្មើសនេះ។[25] គួរកត់សម្គាល់ថា យ៉ាងហោចណាស់បុគ្គល ៥ នាក់ត្រូវបានកាត់ឱ្យមានទោសក្រោមមាត្រា ៤៣៧-ស្ទួន ដោយផ្អែកលើការសន្ទនាជាលក្ខណៈឯកជនដែលរួមមានការហៅទូរស័ព្ទ និងការហៅតាម Zoom។[26]

---

[22] ក្រុមការងារអង្គការសហប្រជាជាតិស្តីពីការឃុំខ្លួនតាមទំនើងចិត្ត មតិយោបល់លេខ ៥/២០២៣ ពាក់ព័ន្ធនឹងសំណុំរឿង សេង ចាន់ធារី (កម្ពុជា) A/HRC/WGAD/2023/5, ទំព័រ៦៧-៧១
ក្រុមការងារអង្គការសហប្រជាជាតិស្តីពីការឃុំខ្លួនតាមទំនើងចិត្ត មតិយោបល់លេខ ៧៥/២០២១ ពាក់ព័ន្ធនឹងសំណុំរឿង រស់ សាខេត (កម្ពុជា) A/HRC/WGAD/2021/75 ទំព័រ៦៤-៦៧

[23] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៤៩៥។

[24] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ, ក.អ.ស.ព.ន/C/GC/៣៤ ទំព័រ៣៨,៤៧

[25] ម.ស.ម.ក,បីឆ្នាំនៃការដាក់ឱ្យអនុវត្តច្បាប់ស្តីពីបទប្រមាថអង្គព្រះមហាក្សត្រ, ខែកុម្ភៈ ឆ្នាំ២០២១(https://tinyurl.com/CCHR-LM-Snapshot ម.ស.ម.ក និងអង្គការសង្គមស៊ីវិល,ការកាត់ទោសសកម្មជនមាតាធម្មជាតិគឺជាអាមាសរបស់ជាតិ(ថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២២)។ https://tinyurl.com/CCHR-Mother-Nature

[26] មាត្រា ១៩, Blog: បទប្រមាថអង្គព្រះមហាក្សត្រធ្វើឱ្យបាត់បង់សេរីភាពខាងការបញ្ចេញមតិនៅតំបន់អាស៊ីអាគ្នេយ៍, ១៩ ខែសីហា ២០២២,https://tinyurl.com/Art-19-lese-majeste។

**មាត្រា ៣០៧ (បទជេរប្រមាថជាសាធារណៈ) មាត្រា ៥២៣ (បទធ្វើឱ្យបាត់ជំនឿលើសេចក្ដីសម្រេចរបស់តុលាការ) និងមាត្រា ៥០២ (បទប្រមាថ)**

មាត្រា ៣០៧ មាត្រា ៥២៣ និងមាត្រា ៥០២ នៃក្រមព្រហ្មទណ្ឌ មិនសូវត្រូវបានប្រើប្រាស់នោះទេ ប៉ុន្តែមាត្រាទាំងនេះក៏បង្កជាការព្រួយបារម្ភច្រើនផងដែរ។ មាត្រាដែលកំណត់ថា "ការប្រមាថ" ជាបទព្រហ្មទណ្ឌជាពិសេស មាត្រា ៥០២ ធ្វើឱ្យមានការមើលរំលងអង្គហេតុដែលថា សេរីភាពខាងការបញ្ចេញមតិផ្ដល់ការការពារចំពោះគំនិត និងយោបល់នានាដែលអាចជាការប្រមាថ ការបង្កការភ្ញាក់ផ្អើល ឬការរំខាន ហើយថាការបញ្ចេញមតិដោយសេរីគឺមានតម្លៃខ្ពស់ជាពិសេសពាក់ព័ន្ធនឹងបុគ្គលសាធារណៈក្នុងជួរនយោបាយ។[27]

គណៈកម្មាធិការសិទ្ធិមនុស្សថ្លែងថា "ការចាត់ទុកអង្គហេតុនៃការបញ្ចេញមតិតែមួយមុខជាការប្រមាថដល់បុគ្គលសាធារណៈគឺមិនទាន់គ្រប់គ្រាន់នោះទេដើម្បីធ្វើជាសំអាងផ្ដន្ទាទោសលើនរណាម្នាក់នោះ"។[28]

**មាត្រា ៤២៥ (បទក្លែងព័ត៌មាន)**

មាត្រា ៤២៥ នៃក្រមព្រហ្មទណ្ឌបានចែងហាមឃាត់ «អំពើផ្ដល់ ឬបើកកកាយព័ត៌មានក្លែងដើម្បីធ្វើឱ្យគេជឿថានឹងកើតមានឡើងនូវការបំផ្លិចបំផ្លាញ ការធ្វើឱ្យទ្រុឌទ្រោមឬការធ្វើឱ្យខូចខាតប្រកបដោយគ្រោះថ្នាក់ចំពោះមនុស្ស»។ ការដាក់ទោសទណ្ឌលើការផ្សព្វផ្សាយព័ត៌មានមិនពិត និងព័ត៌មានក្លែងក្លាយនេះគឺមិនស្របតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិទេ ដែលច្បាប់នេះមិនអនុញ្ញាតឱ្យមានការហាមឃាត់ជាទូទៅចំពោះការបញ្ចេញមតិយោបល់ខុស ឬការបកស្រាយខុសអំពីព្រឹត្តិការណ៍នានាឡើយ។[29]

---

[27] តុលាការសិទ្ធិមនុស្សអ៊ឺរ៉ុប,Handyside v the united Kingdom, App n.៥៤៩៣/៧២( ថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩៧៦ ),ទ៤៩ គណៈកម្មការសិទ្ធិមនុស្ស,ក.អ.ស.ព.ន/C/GC/៣៤,ទ៣៧

[28] ដូចខាងលើ ទំព័រ ៣៨

[29] គណៈកម្មការសិទ្ធិមនុស្ស,សេចក្ដីពន្យល់ទូទៅលេខ៣៤ ទំព័រ៤៩។

ទោះជាយ៉ាងណា ក៏មានចំណុចសំខាន់មួយគឺៈ កាលពីខែសីហា ឆ្នាំ២០២៤ ក្រសួងយុត្តិធម៌បានប្រកាសថាខ្លួនកំពុងស្ថិតក្នុងដំណើរការកែសម្រួលក្រមព្រហ្មទណ្ឌកម្ពុជា ដែលជាក់ស្តែងគឺដើម្បីលើកកម្ពស់ប្រព័ន្ធតុលាការរបស់ប្រទេស ធានាឱ្យស្របតាមបទដ្ឋានអន្តរជាតិ និងប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន។ យោងតាមក្រសួងការងារនេះត្រូវការចូលរួមពីភាគីពាក់ព័ន្ធសំខាន់ៗ ដើម្បីធានាថាការកែទម្រង់នេះស្របទៅតាមតម្រូវការសង្គមបច្ចុប្បន្ន និងអនាគត ហើយថាការកែទម្រង់ទាំងនោះមានគោលបំណងកែលម្អប្រសិទ្ធភាព គុណភាព និងយុត្តិធម៌នៃប្រព័ន្ធតុលាការ ដើម្បីឱ្យវាឆ្លុះបញ្ចាំងពីគោលការណ៍សិទ្ធិមនុស្សជាមូលដ្ឋាន។ ដូច្នេះនេះគឺជាឱកាសដ៏សំខាន់មួយសម្រាប់មាត្រាដែលបានលើកឡើងខាងលើ ត្រូវបានកែសម្រួលឱ្យស្របតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។



## ខ. ច្បាប់ស្តីពីរបបសារព័ត៌មាន

បញ្ញត្តិមួយចំនួនក្នុងច្បាប់ស្តីពីរបបសារព័ត៌មាន ឆ្នាំ១៩៩៥ នៃប្រទេសកម្ពុជាត្រូវបានបង្កើតឡើងដោយបានកំណត់ខ្លឹមសារមិនច្បាស់លាស់ ហើយជាលទ្ធផល បានធ្វើឱ្យមានការរឹតត្បិតមិនត្រឹមលើប្រព័ន្ធផ្សព្វផ្សាយ និងអ្នកសារព័ត៌មាន និងនាំឱ្យពួកគេមានការលំបាកក្នុងការអនុវត្តការងារ ដោយពុំមានការភ័យខ្លាចចំពោះការតបត។ បញ្ញត្តិនេះធ្វើឱ្យប៉ះពាល់ដល់ច្បាប់ស្តីពីរបបសារព័ត៌មានដែលបង្កើតឡើងយ៉ាងល្អ ដើម្បីជួយសម្រួលដល់សេរីភាពសារព័តមានតាមរយៈការដាក់បញ្ចូលបទប្បញ្ញត្តិដែលហាមឃាត់ការត្រួតពិនិត្យមុនចេញផ្សាយ ការពារការសម្ងាត់នៃប្រភព ធានាបាននូវឯករាជ្យភាពនៃអ្នកសារព័ត៌មាន និងអនុញ្ញាតឱ្យសារព័ត៌មានបានដឹងអំពីដំណើរការរបស់រដ្ឋាភិបាល និងតុលាការ។[30]

គួរឱ្យសោកស្តាយ ដែលផ្នែកភាគច្រើននៃច្បាប់ស្តីពីរបបសារព័ត៌មាននេះមិនមានផ្តល់ការការពារបែបនេះនោះទេ ជាពិសេស ផ្នែកនៃច្បាប់ដែលដាក់កម្រិតយ៉ាងតឹងរ៉ឹងលើខ្លឹមសារព័ត៌មានៈ

- មាត្រា ១១ ហាមឃាត់មិនឱ្យសារព័ត៌មានបោះពុម្ពផ្សាយនូវ "អ្វីដែលនាំឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈដោយញុះញង់ដោយផ្ទាល់ឱ្យមនុស្សម្នាក់ ឬច្រើននាក់ប្រព្រឹត្តអំពើហិង្សា" ដែលផ្តន្ទាទោសពិន័យជាប្រាក់ពី១លានរៀល ដល់៥លានរៀល។
- មាត្រា ១២ ហាមឃាត់មិនឱ្យសារព័ត៌មានបោះពុម្ពផ្សាយ ឬផ្សាយបន្តនូវ "ព័ត៌មានដែលបណ្តាលឱ្យប៉ះពាល់ដល់សន្តិសុខជាតិ និងស្ថិរភាពនយោបាយ"ដែលផ្តន្ទាទោសពិន័យជាប្រាក់ពី១លានរៀល ដល់៥លានរៀល ឬក្រសួងព័ត៌មានសិទ្ធិផ្អាកការផ្សាយក្នុងរយៈពេលមិនហួស៣០ថ្ងៃ។
- មាត្រា ១៣ ហាមឃាត់មិនឱ្យសារព័ត៌មានបោះពុម្ពផ្សាយ ឬផ្សាយបន្ត "ការមិនពិតដែលជាការជេរប្រមាថ ការមើលងាយដល់ស្ថាប័នជាតិ"ដែលផ្តន្ទាទោសពិន័យជាប្រាក់ពី២លានរៀល ដល់១០លានរៀល។
- មាត្រា ១៤ ហាមឃាត់មិនឱ្យសារព័ត៌មានបោះពុម្ពផ្សាយនូវ "អ្វីដែលប៉ះពាល់ដល់ប្រពៃណីល្អរបស់សង្គមជាតិ"ដែលផ្តន្ទាទោសពិន័យជាប្រាក់ពី១លានរៀល ដល់៥លានរៀល។

30

ការហាមឃាត់ទាំងនេះផ្តល់ភាពស្របច្បាប់ដល់ការរឹតត្បិតលើសេរីភាពខាងការបញ្ចេញមតិគ្រប់ទម្រង់ ដែលត្រូវបានការពារក្រោមច្បាប់អន្តរជាតិ។ ជាងនេះទៅទៀត ការប្រើពាក្យថា "អាចនាំឱ្យប៉ះពាល់" បង្កើតបាននូវលក្ខខណ្ឌមួយដែលក្នុងនោះមិនចាំបាច់មានការប៉ះពាល់ពិតជាក់ស្តែងនោះទេ ប៉ុន្តែគ្រាន់តែឥទ្ធិពលដែលអាចកើតមានឡើង ក៏ចាត់ចូលទៅក្នុងច្បាប់នេះបានផងដែរ។ ការណ៍នេះបង្កើតបាននូវវិសាលភាពយ៉ាងទូលំទូលាយ ដូច្នេះហើយនាំឱ្យមានការលំបាកកាន់តែខ្លាំងបន្ថែមទៀតក្នុងការគ្រប់គ្រងការបញ្ចេញមតិរបស់ខ្លួនដើម្បីធ្វើយ៉ាងណាឱ្យស្របតាមច្បាប់។

ការដាក់បញ្ចូលពាក្យ «ស្ថិរភាពនយោបាយ» នៅក្នុងមាត្រា ១២ គឺជារឿងដែលគួរឱ្យព្រួយបារម្ភជាពិសេសព្រោះវាអាចត្រូវបានប្រើប្រាស់ក្នុងគោលបំណងបម្រើផលប្រយោជន៍ផ្ទាល់ខ្លួនរបស់គណបក្សនយោបាយ ឬឥស្សរជននយោបាយ ដែលកំពុងកាន់អំណាចដែលជាហេតុធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈ និងគោលការណ៍ប្រជាធិបតេយ្យ។

ច្បាប់នេះក៏មានភាពផ្ទុយគ្នាផងដែរ ដោយសារមាត្រា ១ បានចែងអំពីសេរីភាពសារព័ត៌មានស្របតាមរដ្ឋធម្មនុញ្ញ ហើយមាត្រា ២០ ចែងថា៖ «គ្មានជនណាម្នាក់ត្រូវបានចាប់ខ្លួន ឬត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ដោយសារតែការបញ្ចេញមតិយោបល់ឡើយ»។ ខណៈពេលដែលបទប្បញ្ញត្តិទាំងនេះជាចំណុចវិជ្ជមាននៃច្បាប់ស្តីពីរបបសារព័ត៌មាន វានៅតែត្រូវបានរងផលប៉ះពាល់ដោយសារតែមាត្រា ១១, ១២, ១៣ និង ១៤ ដែលបានកម្រិតដល់សេរីភាពសារព័ត៌មាន និងសមត្ថភាពក្នុងការអនុវត្តសេរីភាពខាងការបញ្ចេញមតិយោបល់។



## គ. ច្បាប់ស្តីពីទូរគមនាគមន៍ (ឆ្នាំ២០១៥) និងប្រកាសអន្តរក្រសួងលេខ ១៧០ ស្តីពីការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម ដែលដំណើរការតាមប្រព័ន្ធអ៊ីនធឺណិតនៅព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ២០១៨)

ច្បាប់ស្តីពីទូរគមនាគមន៍ ដែលបានចូលជាធរមាននៅឆ្នាំ២០១៥ បានបង្កើតឱ្យមានបទល្មើសព្រហ្មទណ្ឌថ្មីៗជាបន្តបន្ទាប់ទាក់ទងនឹងការប្រើប្រាស់ឧបករណ៍ទូរគមនាគមន៍ ដែលការបំពានប្រឈមនឹងការជាប់ពន្ធនាគារ និងពិន័យជាប្រាក់យ៉ាងច្រើន។ បទល្មើសទាំងនេះគឺជាការរឹតត្បិតយ៉ាងធ្ងន់ធ្ងរលើសេរីភាពខាងការបញ្ចេញមតិ។ នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ក្រសួងព័ត៌មាន ក្រសួងមហាផ្ទៃ និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ បានចេញប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម ដែលដំណើរការតាមប្រព័ន្ធអ៊ីនធឺណិតដែលបំពេញបន្ថែមលើច្បាប់នេះ និងពង្រឹងការរឹតត្បិតរបស់ខ្លួន។

មាត្រា ៦៦ នៃច្បាប់ស្តីពីទូរគមនាគមន៍ រួមមានការហាមឃាត់ជាទូទៅលើ "ការបង្កើត ការដំឡើង ការប្រើប្រាស់ និងការកែប្រែហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍... ដែលអាចបង្កការប៉ះពាល់ដល់សណ្តាប់ធ្នាប់ សាធារណៈ និងនាំឱ្យអន្តរាយដល់សន្តិសុខជាតិ ត្រូវហាមឃាត់"។[31] ការផ្តន្ទាទោសចំពោះការរំលោភបំពានលើបទល្មើសនេះ គឺរងការផ្តន្ទាទោសពីប្រាំពីរឆ្នាំ ទៅដប់ប្រាំឆ្នាំ(មាត្រា ៨០)។[32] ស្រដៀងគ្នាទៅនឹងច្បាប់ស្តីពីរបបសារព័ត៌មាន ការប្រព្រឹត្តបទឧក្រិដ្ឋ ក្រោមមាត្រា ៦៦ មិនតម្រូវឱ្យមានមូលហេតុនៃការបង្កគ្រោះថ្នាក់ជាក់ស្តែងនោះទេ ប៉ុន្តែជាសកម្មភាពណាមួយដែល "អាច" ប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬសន្តិសុខជាតិ ត្រូវបានចាត់ទុកថាជាបទឧក្រិដ្ឋ ដែលធ្វើឱ្យការអនុវត្តបទប្បញ្ញត្តិនេះមានលក្ខណៈទូលំទូលាយខ្លាំង។



[31] ច្បាប់ស្តីពីទូរគមនាគមន៍ មាត្រា ៦៦
[32] ដូចខាងលើ, មាត្រា ៨០

ខណៈដែលសន្តិសុខជាតិ និងសណ្តាប់ធ្នាប់សាធារណៈ ជាក់ស្តែងគឺជាមូលដ្ឋានស្របច្បាប់ក្នុងការការរឹតត្បិតសេរីភាពខាងការបញ្ចេញមតិក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ការចាត់ទុកការបញ្ចេញមតិក្នុងទម្រង់ណាមួយថាជាបទឧក្រិដ្ឋនោះ ត្រូវតែបំពេញតាមលក្ខខណ្ឌនៃភាពប្រាកដប្រជាផ្នែកគតិយុត្ត។ ភាពមិនច្បាស់លាស់នៃបទប្បញ្ញត្តិនេះ ហាក់ដូចជាមិនបំពេញតាមលក្ខខណ្ឌនេះឡើយ។ មិនមានការបញ្ជាក់ច្បាស់ទេថាសកម្មភាពណាខ្លះអាចបង្កផលប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ នាំឱ្យបញ្ញត្តិនេះងាយនឹងអនុវត្តតាមទំនើងចិត្ត ។

ខណៈដែលមិនមានបទប្បញ្ញត្តិច្បាប់ជាក់លាក់ណាមួយ ដែលផ្តល់អំណាចច្បាស់លាស់ដល់រដ្ឋាភិបាលដើម្បីបិទប្រព័ន្ធអ៊ីនធឺណិត មាត្រា ៧ ចែងថា៖ "ក្នុងករណីប្រធានសក្តិ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ឬក្រសួង ឬស្ថាប័នមានសមត្ថកិច្ច អាចបញ្ជាទៅប្រតិបត្តិករទូរគមនាគមន៍ដែលពាក់ព័ន្ធឱ្យចាត់វិធានការចាំបាច់ ដោយផ្អែកតាមការសម្រេចរបស់រាជរដ្ឋាភិបាល"។[33] ការដែលមិនមានការពន្យល់បកស្រាយច្បាស់លាស់ថាតើ "វិធានការចាំបាច់" មានអ្វីខ្លះនោះ បង្កើតឱ្យមានសិទ្ធិសេរីភាពទូលំទូលាយក្នុងការសម្រេចចិត្តអំពីវិធានការដែលអាចអនុវត្ត ដូច្នេះហើយការណ៍នេះមិនទាន់ដកចេញនូវលទ្ធភាពក្នុងការចេញបញ្ជាឱ្យបិទអ៊ីនធឺណិតនោះទេ។

លើសពីនេះទៅទៀត មាត្រា ៩៧ បានចែងថា "ការលួចស្តាប់ ឬការលួចថត... ការសន្ទនា ដោយប្រើប្រាស់ប្រព័ន្ធទូរគមនាគមន៍ឯកជន" ត្រូវបានអនុញ្ញាត ប្រសិនបើការណ៍នោះធ្វើឡើង "ដោយមានការអនុញ្ញាតពីអាជ្ញាធរស្របច្បាប់"។ ទោះជាយ៉ាងណាក៏ដោយ មាត្រានេះមិនបានបញ្ជាក់ថាតើអ្វីទៅជា "អាជ្ញាធរស្របច្បាប់" ឬកំណត់ថាត្រូវតែជាអាជ្ញាធរតុលាការនោះទេ។ ហេតុដូច្នេះហើយ ចំណុចនេះបានបើកលទ្ធភាពឱ្យមានការឃ្លាំមើលលើការទំនាក់ទំនង ដែលអាចត្រូវបានអនុញ្ញាតដោយបុគ្គលផ្សេងៗយ៉ាងទូលំទូលាយ និងដោយគ្មានការត្រួតពិនិត្យពីស្ថាប័នតុលាការ។

ប្រកាសអន្តរក្រសួង ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម ("ប្រកាស") មានគោលបំណង "រាំងខ្ទប់ និងទប់ស្កាត់ការបោះពុម្ពផ្សាយ ឬការចែករំលែកខ្លឹមសារព័ត៌មានទាំងអស់ ឬសារជាអក្សរ សំឡេង រូបភាព វីដេអូ និង/ឬទម្រង់ផ្សេងៗទៀត ដែលមានចេតនាបង្កជាចលាចល បណ្តាលឱ្យអន្តរាយដល់វិស័យការពារជាតិ សន្តិសុខជាតិ ទំនាក់ទំនងជាមួយប្រទេសដទៃ សេដ្ឋកិច្ចជាតិ សណ្តាប់ធ្នាប់សាធារណៈ ការរើសអើង និងវប្បធម៌ និងប្រពៃណីជាតិ"។[34] ប្រកាសនេះមានវិសាលភាពអនុវត្តលើ " ខ្លឹមសារព័ត៌មានទាំងអស់ ឬសារជាអក្សរ សំឡេង រូបភាព វីដេអូ និង/ឬទម្រង់ផ្សេងៗទៀត"[35] នៅក្នុង "ការបោះពុម្ពផ្សាយតាមគេហទំព័រ" ក៏ដូចជា "បណ្តាញទំនាក់ទំនងសង្គមគ្រប់ទម្រង់" នៅលើអ៊ីនធឺណិតនៅក្នុងប្រទេសកម្ពុជា[36] ហើយអនុវត្តចំពោះគេហទំព័រ និងរាល់បណ្តាញទំនាក់ទំនងសង្គមទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។[37]

ប្រកាសនេះបង្កើតឱ្យមាន "អង្គភាពជំនាញរួម" ដែលមានតំណាងមកពីក្រសួងព័ត៌មាន ក្រសួងមហាផ្ទៃ និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដែលមានភារកិច្ច "សហការត្រួតពិនិត្យ សិក្សា ស្រាវជ្រាវ ស្វែងរកសកម្មភាពអាជីវកម្ម និងការបោះពុម្ពផ្សាយខុសច្បាប់ នៅលើគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម" និងចាត់វិធានការចំពោះសកម្មភាពទាំងនោះ។[38] យោងតាម ក្រសួងមហាផ្ទៃ អង្គភាពនេះត្រូវបានបង្កើតឡើងដើម្បីប្រយុទ្ធប្រឆាំងនឹងបទល្មើសបច្ចេកវិទ្យា និងអនុវត្តបទប្រមាថចំពោះអង្គព្រះមហាក្សត្រ។[39] ជារួមក្រុមការងារនេះមានសិទ្ធិអំណាចក្នុងការតាមដាន ចែករំលែកព័ត៌មាន ផ្តន្ទាទោស រាំងខ្ទប់ ឬបិទក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត និងចាត់វិធានការផ្លូវច្បាប់ចំពោះបុគ្គលទាំងឡាយណាដែលបំពានប្រកាសនេះ។

---

[33] ដូចខាងលើ មាត្រា ៧
[34] ប្រកាសស្តីពីបណ្តាញទំនាក់ទំនងសង្គម ប្រការ ២
[35] ប្រកាសស្តីពីបណ្តាញទំនាក់ទំនងសង្គម ប្រការ ១
[36] ប្រកាសស្តីពីបណ្តាញទំនាក់ទំនងសង្គម ប្រការ ២
[37] ប្រកាសស្តីពីបណ្តាញទំនាក់ទំនងសង្គម ប្រការ ៣

ប្រកាសនេះកំណត់សកម្មភាពមួយចំនួនជាបទល្មើស រួមមាន៖

- ប្រការ ៨ (ក)៖ ការបង្កចលាចលក្នុងសង្គម
- ប្រការ ៦ (គ)៖ ការផ្សព្វផ្សាយព័ត៌មានដោយចេតនា ដើម្បីបង្កជាចលាចលក្នុងសង្គម
- ប្រការ ៦ (គ) ប្រការ ៨ (ក)៖ បណ្តាលឱ្យអន្តរាយដល់វិស័យការពារជាតិ
- ប្រការ ៦ (គ) ប្រការ ៨ (ក)៖ បណ្តាលឱ្យអន្តរាយដល់សន្តិសុខជាតិ
- ប្រការ ៦ (គ) ប្រការ ៨ (ក)៖ បណ្តាលឱ្យអន្តរាយដល់ទំនាក់ទំនងជាមួយប្រទេសដទៃ
- ប្រការ ៦ (គ) ប្រការ ៨ (ក)៖ បណ្តាលឱ្យអន្តរាយដល់សណ្តាប់ធ្នាប់សាធារណៈ
- ប្រការ ៦ (គ)៖ បណ្តាលឱ្យអន្តរាយដល់សេដ្ឋកិច្ចជាតិ
- ប្រការ ៦ (គ) ប្រការ ៨ (ក)៖ ការបង្កើតឱ្យមានការរើសអើង
- ប្រការ ៦ (គ) ប្រការ ៨ (ក)៖ បណ្តាលឱ្យអន្តរាយដល់វប្បធម៌ និងប្រពៃណីជាតិ
- ប្រការ ៧ (គ)៖ ការផ្សព្វផ្សាយខ្លឹមសារល្មើសច្បាប់ដែលមានលក្ខណៈញុះញង់ បំបែកបំបាក់សាមគ្គី ការរើសអើង ចេតនាបង្កចលាចល ដែលអាចបណ្តាលឱ្យអន្តរាយដល់សន្តិសុខជាតិ ផលប្រយោជន៍សាធារណៈ និងសណ្តាប់ធ្នាប់សង្គម
- ប្រការ ៦ (គ) ប្រការ ៧ (គ) ប្រការ ៨ (ក)៖ ការផ្សព្វផ្សាយ/ការធ្វើប្រតិបត្តិការ "ល្មើសច្បាប់" (ប្រការ ៦ (គ) ៧ (គ) ៨ (ក))
- ការធ្វើអាជីវកម្មខុសច្បាប់
- ប្រការ ៨ (គ)៖ ការផ្សព្វផ្សាយព័ត៌មាន ឬសារជាអក្សរ សំឡេង រូបភាព វីដេអូ និង/ឬ ទម្រង់ផ្សេងៗទៀតដែលល្មើសច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

បន្ថែមលើបទប្បញ្ញត្តិទាំងនេះ ប្រកាសនេះចេញបទបញ្ជាឱ្យក្រុមហ៊ុនផ្តល់សេវាអ៊ីនធឺណិត ទាំងអស់ "មានកម្មវិធីសូហ្វវែរ និងបំពាក់ឧបករណ៍គ្រប់គ្រងអ៊ីនធឺណិត ដើម្បីងាយស្រួលក្នុងការច្រោះ (Filter) និងធ្វើការរាំងខ្ទប់ (Block) ចំពោះគណនីបណ្តាញទំនាក់ទំនងសង្គម ឬទំព័រ (Page) នានា "ដែលខុសច្បាប់" ហើយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ធ្វើការ "រាំងខ្ទប់ ឬបិទ" គេហទំព័រ និងទំព័របណ្តាញទំនាក់ទំនងសង្គមដែលមានខ្លឹមសារ "ក្នុងលក្ខណៈញុះញង់ បំបែកបំបាក់សាមគ្គីភាព ការរើសអើង ចេតនាបង្កចលាចល ដែលអាចបណ្តាលឱ្យអន្តរាយដល់សន្តិសុខជាតិ ផលប្រយោជន៍សាធារណៈ និងសណ្តាប់ធ្នាប់សង្គម"។

វិធានការនេះបង្កើតឱ្យមានការបំពានលើសេរីភាពខាងការបញ្ចេញ មតិដោយ មិនត្រឹមត្រូវ និង គ្មានសមភាព។ ទោះបីជាការរឹតត្បិតទាំងនេះមានចែងនៅក្នុងលិខិតបទដ្ឋានគតិយុត្តក៏ដោយ ប៉ុន្តែខ្លឹមសារក្នុងនោះមានលក្ខណៈទូលំទូលាយ និងមិនច្បាស់លាស់នាំឱ្យបុគ្គលពិបាកក្នុងការយល់ និងអនុវត្តសកម្មភាពស្របតាម ដូច្នេះហើយការរឹតត្បិតទាំងនេះមិនអាចនិយាយបានថាមានចែងក្នុងច្បាប់នោះទេ។ ជាពិសេស ពាក្យដូចជា "ខ្លឹមសារល្មើសច្បាប់" "មានចេតនាបង្កចលាចល" ឬ "សកម្មភាពអាជីវកម្មខុសច្បាប់" គឺមានលក្ខណៈស្រពិចស្រពិល និងទូលំទូលាយខ្លាំងណាស់។

---

[38] ប្រកាសស្តីពីបណ្តាញទំនាក់ទំនងសង្គម ប្រការ ៤

[39] កាន់ វិច្ឆិកា "កម្ពុជាបង្កើតក្រុមការងារដើម្បីតាមដាន "ព័ត៌មានក្លែងក្លាយ" នៅលើបណ្តាញទំនាក់ទំនងសង្គម វិទ្យុសំឡេងសហរដ្ឋអាមេរិក (ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨) https://www.voacambodia.com/a/cambodia-forms-task-force-to-monitor-fake-news-on-social-media/4425534.html.

ប្រការ ២ នៃប្រកាសនេះដាក់ចេញប្រាំបីចំណុចដែលគាំទ្រដល់ការអនុម័ត រួមមាន ការការពារ "វិស័យការពារជាតិ" "សន្តិសុខជាតិ" "ទំនាក់ទំនងជាមួយប្រទេសដទៃ" "សេដ្ឋកិច្ចជាតិ" "សណ្តាប់ធ្នាប់សាធារណៈ" "ការរើសអើង" "វប្បធម៌ " និង "ប្រពៃណីជាតិ "។

"សេដ្ឋកិច្ចជាតិ" មិនអាចបង្កើតបានជាគោលបំណងស្របច្បាប់ទេ។ ពាក្យថា "វប្បធម៌ជាតិ" និង "ប្រពៃណី" មានលក្ខណៈទូលំទូលាយខ្លាំងពេក ដូច្នេះហើយងាយនឹងប្រើប្រាស់ខុស។ ពាក្យទាំងនេះអាចកំណត់ជាគោលបំណងស្របច្បាប់បាន ដែលស្ថិតក្រោម «សីលធម៌សាធារណៈ»។

នៅពេលដែលសន្តិសុខជាតិត្រូវកំណត់ជាមូលដ្ឋានច្បាប់សម្រាប់ការរឹតត្បិតលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិ ការភ្ជាប់ទំនាក់ទំនងដោយផ្ទាល់ និងភ្លាមៗរវាងការបញ្ចេញមតិ និងការគំរាមកំហែងដែលបានអះអាងនោះត្រូវតែបង្កើតឡើង។[40] ការណ៍នេះត្រូវបង្ហាញថា (ក) ការបញ្ចេញមតិនោះមានបំណងញុះញង់ឱ្យជិតកើតមានអំពើហិង្សា (ខ) ទំនងជាការញុះញង់ឱ្យមានអំពើហិង្សា និង (គ) មានទំនាក់ទំនងដោយផ្ទាល់ និងភ្លាមៗរវាងមតិនោះ និងលទ្ធភាពដែលអាចកើតមានអំពើហិង្សានោះ។[41] ការប្រើប្រាស់ "សន្តិសុខជាតិ" ជាមូលដ្ឋានដើម្បីរឹតត្បិតលើការបញ្ចេញមតិគួរកំណត់ត្រឹមតែចំពោះ "ស្ថានភាពដែលអាចបង្កផលប៉ះពាល់ដល់ផលប្រយោជន៍ជាតិទាំងមូលប៉ុណ្ណោះ ដែលត្រង់ចំណុចនេះមិនរាប់បញ្ចូលការរឹតត្បិតដើម្បីផលប្រយោជន៍តែមួយគត់របស់រដ្ឋាភិបាល របបដឹកនាំ ឬក្រុមអ្នកមានអំណាច...។ ស្រដៀងគ្នានេះដែរ សណ្តាប់ធ្នាប់សាធារណៈត្រូវកំណត់ត្រឹមតែចំពោះស្ថានភាពជាក់លាក់ប៉ុណ្ណោះដែលក្នុងនោះការដាក់កំហិត [ចំពោះការបញ្ចេញមតិ] ត្រូវផ្អែកលើមូលហេតុច្បាស់លាស់ "។[42]

សកម្មភាពដែលកំណត់ភាពត្រឹមត្រូវនៃការរឹតត្បិតសេរីភាពខាង ការបញ្ចេញមតិមិន ត្រូវបានបកស្រាយនៅក្នុងប្រកាសនោះឡើយ។ ផ្ទុយទៅវិញ ភាសាដែលប្រើពីដើមដល់ចប់មានន័យទូលំទូលាយ និងមានភាពមិនច្បាស់លាស់ខ្លាំងណាស់។ ឧទាហរណ៍ដូចជាពាក្យថា "ព័ត៌មានក្លែងក្លាយ" " ផ្សព្វផ្សាយដែលល្មើសច្បាប់" "ចលាចលក្នុងសង្គម" "ទំនាក់ទំនងជាមួយប្រទេសដទៃ" "ខ្លឹមសារខុសច្បាប់" និង "សកម្មភាពខុសច្បាប់" មិនមាននិយមន័យគ្រប់គ្រាន់ ដើម្បីកំណត់ការរឹតត្បិតដែលសមហេតុផល និងមានសមាមាត្រមកលើសេរីភាពខាងការបញ្ចេញមតិ។

បន្ថែមពីនេះ ផលប៉ះពាល់យ៉ាងទូលំទូលាយនៃប្រកាសនេះ ដែលរួមមានដូចជា ការបាត់បង់ឯកជនភាពតាមអនឡាញ ការព្យួរគេហទំព័រ ការបិទគណនីបណ្តាញទំនាក់ទំនងសង្គម និងមិនមានការលើកឡើងអំពីការត្រួតពិនិត្យរបស់តុលាការ ឬការទាមទារណាមួយដែលអាចធ្វើទៅបាន ចំពោះអ្នកដែលចង់តវ៉ាប្រឆាំងនឹងសកម្មភាពដែលអនុវត្តដោយអង្គភាពជំនាញ គឺមានន័យថា វិសាលភាពអនុវត្តរបស់ប្រកាសនេះមានលក្ខណៈមិនសមាមាត្រយ៉ាងខ្លាំងបើធៀបនឹងគោលបំណងដែលបានចែង ហេតុដូច្នេះហើយប្រកាសនេះមិនអនុលោមតាមច្បាប់សិទ្ធិមនុស្សឡើយ។

---

[40] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ "សេចក្តីពន្យល់ទូទៅលេខ ៣៤, 'មាត្រា ១៩៖ សេរីភាពក្នុងការបញ្ចេញមតិ និងយោបល់", ក.អ.ស.ព.ន. /C/GC/៣៤, (ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១១) កថាខណ្ឌ ៣៥

[41] ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ, "សេចក្តីរាយការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីការលើកកម្ពស់ និងការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងយោបល់" ឯកសាររបស់អង្គការសហប្រជាជាតិ A/HRC/១៧/២៧ (ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១១) កថាខណ្ឌ ៧៣

[42] ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ, "សេចក្តីរាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីការលើកកម្ពស់ និងការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងយោបល់", ឯកសាររបស់អង្គការសហប្រជាជាតិ A/៧១/៣៧៣ (ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៦) កថាខណ្ឌ ១៨

## ឃ. ធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន និងបណ្ណសម្គាល់អ្នកសារព័ត៌មាន

ក្រសួងព័ត៌មានបានប្រកាសឱ្យអនុវត្តធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន ក្នុងខែសីហា ឆ្នាំ២០២៤ ដោយប្រើហេតុផលថាជាការគាំទ្រប្រព័ន្ធផ្សព្វផ្សាយ។[43]

នៅក្នុងសិក្ខាសាលាពិគ្រោះយោបល់មួយដែលរៀបចំឡើងដោយក្រសួង ជាមួយសមាគមប្រព័ន្ធផ្សព្វផ្សាយ និងអ្នកសារព័ត៌មាន រដ្ឋមន្ត្រីបានសង្កត់ធ្ងន់ថា ឧបករណ៍ទាំងនេះគឺចាំបាច់ដើម្បីដោះស្រាយការរីករាលដាលនៃព័ត៌មានក្លែងក្លាយ ហើយថា"កង្វះប្រភពច្បាស់លាស់" និង "ការពន្យល់របស់ភាគីពាក់ព័ន្ធ" នៅក្នុងអត្ថបទព័ត៌មានបានធ្វើឱ្យប៉ះពាល់ដល់ទំនុកចិត្តរបស់សាធារណជន។[44] ភាគីពាក់ព័ន្ធមានពេលត្រឹមតែប្រាំបួនថ្ងៃប៉ុណ្ណោះ ដើម្បីផ្តល់ធាតុចូលដល់សេចក្តីព្រាងច្បាប់ ហើយធម្មនុញ្ញនឹងត្រូវអនុម័តក្នុងពេលបួនថ្ងៃបន្ទាប់ ដែលជាការរារាំងដល់ការពិភាក្សាបន្ថែមពីភាគីពាក់ព័ន្ធអំពីរបៀបក្នុងការបញ្ចូលមតិយោបល់របស់ពួកគេនៅក្នុងសេចក្តីព្រាង។[45]

ដូចដែល ម.ស.ម.ក ធ្លាប់បានបង្ហាញរួចមកហើយអំពីការព្រួយបារម្ភ ដែលថាវិសាលភាពនៃធម្មនុញ្ញ និងយន្តការអនុវត្តដែលពាក់ព័ន្ធមានភាពមិនច្បាស់លាស់ បង្កឱ្យមានការព្រួយបារម្ភថា ធម្មនុញ្ញនេះនឹងត្រូវបានអនុវត្តតាមអំពើចិត្ត និងដោយរើសមុខ។ អ្វីដែលជាការព្រួយបារម្ភបន្ថែមទៀតនោះ គឺកង្វះការផ្តល់អាទិភាពដល់ប្រយោជន៍សាធារណៈ វិធានការបុរេសកម្មសម្រាប់ការផ្ទៀងផ្ទាត់ព័ត៌មានមុនពេលបោះពុម្ពផ្សាយ និងជាពិសេស លទ្ធភាពក្នុងការប្រើប្រាស់ធម្មនុញ្ញនេះដើម្បីរាំងខ្ទប់មតិរិះគន់ ឬរបាយការណ៍ដែលកំណត់ថាប៉ះពាល់ដល់បុគ្គលមានឥទ្ធិពល។ ការហាមឃាត់ក្នុងធម្មនុញ្ញចំពោះការផ្សព្វផ្សាយខ្លឹមសារដែល "ប៉ះពាល់ដល់វប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់ល្អរបស់ប្រទេសជាតិ" អាចមានហានិភ័យដែលនាំឱ្យមានការបកស្រាយយ៉ាងទូលំទូលាយថាជាការបិទបាំងខ្លឹមសារអនឡាញដែលរិះគន់រដ្ឋាភិបាល។[46] អ្នករាយការណ៍ពិសេសមួយចំនួនរបស់អង្គការសហប្រជាជាតិអំពាវនាវឱ្យរដ្ឋាភិបាល ព្យួរធម្មនុញ្ញ និងពិនិត្យឱ្យបានហ្មត់ចត់ និងធ្វើកំណែទម្រង់ ព្រមទាំងការពារ និងលើកកម្ពស់ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ សេរី និងពហុភាព ដែលជាសសរស្តម្ភសំខាន់នៃលទ្ធិប្រជាធិបតេយ្យ។[47]

ការដាក់ចេញនូវធម្មនុញ្ញនេះបានកើតឡើងស្របពេលដែលក្រសួងព័ត៌មានបានប្រកាសថា បណ្ណសំគាល់អ្នកសារព័ត៌មាននឹងត្រូវបានធ្វើជាឌីជីថល។[48] បណ្ណទាំងនោះត្រូវបានដាក់ឱ្យប្រើប្រាស់ដើម្បីធានានូវភាពត្រឹមត្រូវ និងការពារការក្លែងបន្លំបណ្ណសម្គាល់អ្នកសារព័ត៌មាន និងក្នុងគោលបំណងរក្សាកំណត់ត្រាច្បាស់លាស់របស់អ្នកសារព័ត៌មាននៅក្នុងប្រទេស។[49] យោងតាមគណៈកម្មាធិការសិទ្ធិមនុស្ស ប្រព័ន្ធចុះបញ្ជីរដ្ឋ ឬប្រព័ន្ធផ្តល់អាជ្ញាប័ណ្ណសម្រាប់អ្នកសារព័ត៌មានគឺមិនស្របគ្នានឹងមាត្រា ១៩(៣) នោះទេ។ គម្រោងទទួលស្គាល់មានកំណត់នោះ ត្រូវបានអនុញ្ញាតសម្រាប់តែគោលបំណងផ្តល់ជូនអ្នកសារព័ត៌មាននូវអភ័យឯកសិទ្ធិ ក្នុងការចូលទៅកាន់ទីកន្លែង និង/ឬព្រឹត្តិការណ៍ណាមួយប៉ុណ្ណោះ។

---

[43] ម.ស.ម.ក,ធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មានត្រូវបានអនុវត្តយ៉ាងឆាប់រហ័ស ត្រឹមតែប៉ុន្មានថ្ងៃបន្ទាប់ពីផុតកំណត់ការប្រមូលធាតុចូល

[44] ម.ស.ម.ក "ស្ថានភាពនៃសេរីភាពក្នុងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន( ឆ្នាំ២០២៤ ) ទំ. ៧-៨

[45] ម.ស.ម.ក "ស្ថានភាពនៃសេរីភាពក្នុងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលព័ត៌មាន( ឆ្នាំ២០២៤ ) ទំ. ៧-៨

[46] ដូចខាងលើ

[47] OHCHR, "ប្រទេសកម្ពុជា៖ អ្នកជំនាញអង្គការសហប្រជាជាតិអំពាវនាវឱ្យផ្អាកធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន" ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៤ https://tinyurl.com/ys3726mp

[48] Khmer Times, ក្រសួងព័ត៌មានចាប់ផ្តើមដាក់អេបចុះឈ្មោះអ្នកសារព័ត៌មានដើម្បីទទួលបានបណ្ណសំគាល់អ្នកសារព័ត៌មាន( ទី៤ ខែមីនា ឆ្នាំ២០២៥ )

[49] ម.ស.ម.ក "ស្ថានភាពនៃសេរីភាពក្នុងការបញ្ចេញមតិ សេរីភាពសារព័ត៌មាន និងសិទ្ធិទទួលបានព័ត៌មាន( ឆ្នាំ២០២៤ ) ទំ. ១៥

## ខ. អនុក្រឹត្យស្តីពីបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ

អនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិដែលរៀបចំឡើងដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្នុងខែកក្កដា ឆ្នាំ២០២០ បានចែងថា ចរាចរណ៍អ៊ីនធឺណិតទាំងអស់ដែលចរាចរ និងចូលមកក្នុងប្រទេសកម្ពុជា ត្រូវបញ្ជូនតាមរយៈច្រកទ្វារតែមួយ។ គោលបំណងដែលបានបញ្ជាក់នៃច្រកទ្វារអ៊ីនធឺណិតជាតិ យោងតាមមាត្រា១ នៃអនុក្រឹត្យ គឺដើម្បីសម្រួល និងគ្រប់គ្រងការតភ្ជាប់បណ្តាញអ៊ីនធឺណិត ដើម្បីពង្រឹងប្រសិទ្ធភាព និងសក្តិសិទ្ធភាពនៃការកៀរគរចំណូលជាតិ ការការពារសន្តិសុខជាតិ និង "ការថែរក្សារបៀបរៀបរយសណ្តាប់ធ្នាប់សង្គម វប្បធម៌ និងប្រពៃណីជាតិ"។

យ៉ាងណាមិញ ម.ស.ម.ក អង្គការសង្គមស៊ីវិលកម្ពុជា និងអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិជាច្រើនផ្សេងទៀត បានសង្កត់ធ្ងន់ថា អនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ ផ្តល់ជូនរាជរដ្ឋាភិបាលនូវមធ្យោបាយដើម្បីតាមដាន និងឃ្លាំមើលសកម្មភាពអ៊ីនធឺណិត ស្ទាក់ចាប់ និងត្រួតពិនិត្យការទំនាក់ទំនងឌីជីថល និងអនុញ្ញាតឱ្យមានការប្រមូល ការរក្សាទុក និងការចែករំលែកទិន្នន័យផ្ទាល់ខ្លួន។[50] អំណាចដ៏ទូលំទូលាយបែបនេះ មិនត្រឹមតែធ្វើឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងសិទ្ធិទទួលព័ត៌មានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប៉ះពាល់ដល់សិទ្ធិឯកជនភាពផងដែរ។

មាត្រា ៦ ចែងថា ប្រតិបត្តិករនៃច្រកទ្វារអ៊ីនធឺណិតជាតិ ដែលត្រូវបានតែងតាំងដោយរដ្ឋាភិបាល អាចទប់ស្កាត់ ឬផ្តាច់ការតភ្ជាប់ ឬខ្លឹមសារណាមួយនៅលើប្រព័ន្ធអនឡាញ ដែលត្រូវបានចាត់ទុកថា «ប៉ះពាល់ដល់សន្តិសុខ ចំណូលជាតិ សណ្តាប់ធ្នាប់សង្គម សេចក្តីថ្លៃថ្នូរ វប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់»។ ការតាក់តែងមាត្រានេះមានលក្ខណៈទូលំទូលាយជ្រុល ហេតុដូច្នេះហើយ វាអាចអនុញ្ញាតឱ្យអាជ្ញាធរធ្វើការតាមដានយ៉ាងទូលំទូលាយនូវការទំនាក់ទំនងឯកជននៅលើប្រព័ន្ធអនឡាញ ដោយគ្មានការផ្តល់មូលដ្ឋានច្បាស់លាស់សម្រាប់ធ្វើដូច្នេះឡើយ ហើយក៏អាចអនុញ្ញាតឱ្យមានការត្រួតពិនិត្យយ៉ាងទូលំទូលាយលើខ្លឹមសារអនឡាញផងដែរ ដោយសារតែភាពស្រពិចស្រពិលនៃលក្ខខណ្ឌ។ ដូច្នេះហើយ វាមិនអនុលោមតាមការរឹតត្បិតដែលអាចអនុញ្ញាត លើការអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិ ក្រោមមាត្រា ១៩ (៣) ឡើយ ជាពិសេសទាក់ទងនឹងភាពច្បាស់លាស់ផ្នែកច្បាប់។[51] លើសពីនេះ «ចំណូលជាតិ» មិនមែនជាគោលបំណងស្របច្បាប់មួយ ដែលការអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិ ដែលត្រូវរឹតត្បិតនោះទេ។

មាត្រា ១៤ ចែងថា ប្រតិបត្តិករនៃច្រកទ្វារអ៊ីនធឺណិតជាតិ «រៀបចំ និងរក្សាកំណត់ត្រាបច្ចេកទេស និងបញ្ជីរាយនាមអាសយដ្ឋាន IP ដែលបានបែងចែក និងអត្តសញ្ញាណនៃចរាចរណ៍ដែលឆ្លងកាត់តាមរយៈច្រកទ្វារអ៊ីនធឺណិតជាតិ រៀបចំនិងរក្សារបាយការណ៍ និងឯកសារពាក់ព័ន្ធនានាទាក់ទងនឹងការតភ្ជាប់ និងចរាចរណ៍អ៊ីនធឺណិតទាំងអស់» ដោយមិនបានបញ្ជាក់ពីតម្រូវការសម្រាប់មូលហេតុ ឬគោលបំណងណាមួយក្នុងការធ្វើដូច្នេះទេ។ ហេតុដូច្នេះ វាអនុញ្ញាតឱ្យមានការប្រមូលផ្តុំប្រវត្តិរូបសម្រាប់អ្នកប្រើប្រាស់ ឬអង្គការមួយចំនួន ដោយគ្មានគោលបំណងដែលបាន

---

[50] ម.ស.ម.ក, របាយការណ៍ប្រចាំឆ្នាំទីទ៦នៃការឃ្លាំមើលសេរីភាពមូលដ្ឋាន, https://tinyurl.com/FFMP-22,ទំ.៧-១០។

[51] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ,ក.អ.ស.ព.ន/C/GC/៣៤,ឧ២៤-២៥

បញ្ជាក់ ដែលបង្កើនកង្វល់ថា បុគ្គល ឬអង្គការណាដែលត្រូវបានចាត់ទុកថារិះគន់អាជ្ញាធរ អាចនឹងត្រូវបានទទួលរងនូវការតាមដានបែបនេះ។ ដូច្នេះហើយ វាមិនបំពេញតាមការប្ដឹងថ្លែងភាពចាំបាច់ និងសមាមាត្រសម្រាប់ការរឹតត្បិតដែលអាចអនុញ្ញាតបាន លើសេរីភាពខាងការបញ្ចេញមតិ ក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិឡើយ។[52] មាត្រាដដែលនេះក៏អនុញ្ញាតឱ្យប្រតិបត្តិកររក្សាទុកទិន្នន័យចរាចរណ៍រយៈពេលមួយឆ្នាំ និងផ្ដល់ព័ត៌មានបណ្ដាញផ្សេងទៀត តាមការស្នើសុំរបស់អាជ្ញាធរផងដែរ។

លើសពីនេះ មាត្រា ១៦ ចែងអំពីការពិន័យដ៏ទូលំទូលាយជ្រុលសម្រាប់ប្រតិបត្តិករទូរគមនាគមន៍ដែលមិនអនុលោមតាមច្បាប់ ដែលវានឹងមិនបំពេញតាមការប្ដឹងថ្លែងនៃភាពសមាមាត្រ ក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិឡើយ។

ទោះបីជាអនុក្រឹត្យនេះត្រូវបានចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រីក្នុងខែកុម្ភៈ ឆ្នាំ២០២១ ហើយច្រកទ្វារអ៊ីនធឺណិតជាតិ គ្រោងនឹងអនុវត្តចាប់ពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២២ ក៏ដោយ រដ្ឋាភិបាលបានពន្យារពេលការអនុវត្តដែលបានគ្រោងទុកនោះ ដោយមិនបានកំណត់កាលបរិច្ឆេទច្បាស់លាស់។ មូលហេតុនៃការពន្យារពេលដែលបានលើកឡើងនោះគឺខុសៗគ្នា ដោយអ្នកនាំពាក្យរដ្ឋាភិបាលមួយចំនួនបានលើកឡើងថា ដោយសារតែជំងឺកូវីដ-១៩ ហើយអ្នកផ្សេងទៀតបានលើកឡើងថាមកពីបញ្ហាប្រឈមនៃហេដ្ឋារចនាសម្ព័ន្ធ។[53] ទោះជាយ៉ាងណា នៅក្នុងខែតុលា ឆ្នាំ២០២៥ ប្រព័ន្ធផ្សព្វផ្សាយបានរាយការណ៍ថា ឯកសារមួយពីក្រសួងផែនការដែលមានចំណងជើងថា «ការដំឡើង និងការគ្រប់គ្រងច្រកទ្វារអ៊ីនធឺណិតជាតិ» ដែលចុះកាលបរិច្ឆេទខែឧសភា ឆ្នាំដដែលនោះបានរួមបញ្ចូលនូវព័ត៌មានលម្អិតអំពីផែនការរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីចាប់ផ្ដើមការងារលើហេដ្ឋារចនាសម្ព័ន្ធច្រកទ្វារអ៊ីនធឺណិតជាតិ នៅឆ្នាំ២០២៦។[54] យោងតាមរបាយការណ៍របស់ប្រព័ន្ធផ្សព្វផ្សាយលើឯកសារនោះ វាបានចែងថា «តាមរយៈការប្រើប្រាស់ទិន្នន័យធំ បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត រាជរដ្ឋាភិបាលអាចវិភាគ និងគ្រប់គ្រងការផ្សាយប្រព័ន្ធផ្សព្វផ្សាយសង្គម»។[55] ទោះជាយ៉ាងណាក៏ដោយ នៅពេលផ្សព្វផ្សាយការវិភាគផ្លូវច្បាប់នេះ ព័ត៌មាននេះមិនទាន់ត្រូវបានប្រកាសជាសាធារណៈដោយរាជរដ្ឋាភិបាលនៅឡើយទេ។ ប្រសិនបើផែនការដែលបានបញ្ជាក់នេះជាការពិត ការវិវឌ្ឍមួយដែលគួរឱ្យព្រួយបារម្ភក្នុងការអនុវត្ត។

---

[52] ដូចខាងលើ ទំព័រ២២។

[53] អ្នកការពារសិទ្ធិស៊ីវិល កម្ពុជាគួរលុបចោលច្រកទ្វារអ៊ីនធឺណិតជាតិដែលជាការរំលោភលើសិទ្ធិ ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២២https://tinyurl.com/CRD-statement-NIG

[54] Nikkei Asia, កម្ពុជារៀបចំផែនការឡើងវិញលើច្រកទ្វារអ៊ីនធឺណិតដ៏ចម្រូងចម្រាស់, ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២២ https://tinyurl.com/Nikkei-Asia-NIG

[55] ដូចខាងលើ

# ផ្នែកទី III

# សេចក្ដីព្រាងច្បាប់ និងគោលនយោបាយដែលប៉ះពាល់ដល់សិទ្ធិទទួលបានសេរីភាពខាងការបញ្ចេញមតិ សិទ្ធិទទួលព័ត៌មាន និងឯកជនភាពតាមអ៊ីនធឺណិត



ដោយបានគូសបញ្ជាក់ពីបទប្បញ្ញត្តិច្បាប់ និងគោលនយោបាយដែលមានស្រាប់ ដែលរឹតត្បិតការអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិនៅក្នុងប្រទេសកម្ពុជា យើងក៏គួរតែពិចារណាដែរថាតើសេចក្តីព្រាងច្បាប់បច្ចុប្បន្នអាចជាហានិភ័យក្នុងការរឹតត្បិតបន្ថែមទៀតចំពោះការទទួលបានសិទ្ធិនេះដែរឬទេ។

## គ. សេចក្តី ព្រាង ច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យា

ដំណើរការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យា បានដំណើរការចាប់តាំងពីឆ្នាំ២០១០ ដោយមានកំណែយ៉ាងតិចចំនួនបីដែលត្រូវបានបង្កើតឡើងចាប់តាំងពីពេលនោះមក។ នៅឆ្នាំ២០២៥ សេចក្តីព្រាងច្បាប់ចុងក្រោយបង្អស់ត្រូវបានបង្កើតឡើង។ ដូចគ្នាទៅនឹងសេចក្តីព្រាងមុនៗដែរ សេចក្តីព្រាងនេះនៅតែមានបទប្បញ្ញត្តិដែលគួរឱ្យព្រួយបារម្ភ ហើយនឹងមានផលប៉ះពាល់អវិជ្ជមានដល់សិទ្ធិសេរីភាពខាងការបញ្ចេញមតិ ប្រសិនបើសេចក្តីព្រាងច្បាប់នេះត្រូវបានអនុម័តក្នុងទម្រង់បច្ចុប្បន្ន។

យោងតាមមាត្រា ១ នៃសេចក្តីព្រាងច្បាប់ គោលបំណងនៃច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យា គឺដើម្បីធានានូវភាពសុចរិតភាពការប្រើប្រាស់ និងការគ្រប់គ្រងប្រព័ន្ធកុំព្យូទ័រ និងទិន្នន័យកុំព្យូទ័រ ការពារសន្តិសុខ និង សណ្តាប់ធ្នាប់សាធារណៈ និងការពារសិទ្ធិបុគ្គលដោយកំណត់វិធានការដើម្បីទប់ស្កាត់ បង្ការ និងបង្ក្រាបបទល្មើសបច្ចេកវិទ្យា។ ទោះជាយ៉ាងណា បទប្បញ្ញត្តិជាច្រើនបានធ្វើឱ្យការអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិក្លាយជាបទល្មើស និងមានការផ្តន្ទាទោសដែលមិនសមាមាត្រ ដោយមាត្រាទាំងនោះប្រើប្រាស់ពាក្យដែលមានន័យទូលំទូលាយ និងគ្មានភាពច្បាស់លាស់។

មាត្រា ៤២ ស្តីពី "ការរំលោភបំពានទាក់ទងនឹងបច្ចេកវិទ្យាព័ត៌មាន" ចែងថា បុគ្គលណា "បង្កការបំភិតបំភ័យ គំរាមកំហែង រំលោភបំពានដល់អ្នកដទៃដោយចេតនា ដោយមធ្យោបាយពាក់ព័ន្ធនឹងបច្ចេកវិទ្យាព័ត៌មាន អាចប្រឈមមុខនឹងការជាប់ពន្ធនាគារចាប់ពីមួយខែ ដល់ពីរឆ្នាំ និងពិន័យជាប្រាក់ពី ២ លានរៀល ទៅ ១០ លានរៀល"។ មិនមានការកំណត់និយមន័យសម្រាប់ពាក្យ "ការបំភិតបំភ័យ ការគំរាមកំហែង ឬការរំលោភបំពាន"ទេ ជាពិសេសគឺអាស្រ័យលើការប្រើប្រាស់ "មូលហេតុ" ដែលត្រង់នេះមានន័យថាគោលដៅគឺផ្អែកលើផលប៉ះពាល់ជាក់ស្តែង ជាជាងសកម្មភាពដែលបុគ្គលនោះបានប្រព្រឹត្ត។ ហេតុដូច្នេះហើយ ភាពមិនច្បាស់លាស់ទាំងនេះ មិនបំពេញតាមលក្ខខណ្ឌនៃភាពប្រាកដប្រជាផ្នែកគតិយុត្ត ដើម្បីអាចឱ្យបុគ្គលគ្រប់គ្រងសកម្មភាពរបស់ពួកគេស្របតាមច្បាប់នោះទេ។

មាត្រា ៤៣ ស្តីពី "បទបរិហារកេរ្តិ៍" ដែលចែងថា "ការអះអាងបំផ្លើស ឬទម្លាក់កំហុសដោយអសុទ្ធចិត្ត លើអំពើណាមួយដែលប៉ះពាល់ដល់កិត្តិយស ឬកត្តិស័ព្ទនៃបុគ្គល ឬស្ថាប័នតាមរយៈបច្ចេកវិទ្យាព័ត៌មាន" គឺជារឿងគួរឱ្យព្រួយបារម្ភ។ វោហាសាស្ត្រ ឬការបង្ហាញមតិនោះត្រូវបានបំផ្លើស ទោះជាតាមរយៈអារម្មណ៍ ឬភាសា ឬឃ្លាដែលបង្ហាញពីមតិក្តី មិនមែនជាហេតុផលដែលអាចទទួលយកបានសម្រាប់ការរឹតត្បិតនោះទេ។ ការហាមឃាត់ការលើកឡើងលើសពីការពិតដែលតឹងរឹងបែបនេះធ្វើឱ្យប៉ះពាល់ដល់សិទ្ធិខាងការបញ្ចេញការយល់ឃើញ និងមតិផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់យ៉ាងធ្ងន់ធ្ងរព្រមទាំងរាំងខ្ទប់ការបង្ហាញអារម្មណ៍របស់បុគ្គលនោះផងដែរ។ ការនិយាយលើសពីការពិតអាចត្រូវបានលើកឡើងថាជាការការពារទប់នឹងការបរិហារកេរ្តិ៍ ក្រោមគោលការណ៍ការបំផ្លើសវោហាសាស្ត្រដែលសេចក្តីថ្លែងការណ៍នេះគឺជាការបំផ្លើសជាក់ស្តែង និងមិនមានន័យថាត្រូវយកជាការពិតនោះទេ។[56] ដូច្នេះ សេចក្តីថ្លែងការណ៍លើសពីការពិតទាំងនេះ មិនត្រូវបានចាត់ទុកថាជាសេចក្តីថ្លែងការណ៍នៃការពិតនោះទេ និងជារឿងសំខាន់សម្រាប់ករណីបរិហារកេរ្តិ៍ ហើយការបញ្ជាក់ថាការអះអាងនោះជាការពិត ឬមិនពិតទៅវិញទេដែលជាធាតុចាំបាច់។ ការប្រើប្រាស់ឃ្លា "ទម្លាក់

[56] មាត្រា ១៩ និយមន័យនៃការបរិហារកេរ្តិ៍ – គោលការណ៍ស្តីពីសេរីភាពក្នុងការបញ្ចេញមតិ និងការការពារកេរ្តិ៍ឈ្មោះ ទំ.១២-១៣ https://tinyurl.com/Article-19-Defamation

កំហុសដោយអសុទ្ធចិត្ត" ក៏គួរឱ្យព្រួយបារម្ភផងដែរ ព្រោះភាពសុទ្ធចិត្ត ឬអសុទ្ធចិត្តនៃសេចក្ដីថ្លែងមិនមែនជាកត្តាក្នុងការបញ្ជាក់ ឬបដិសេធការអះអាងបរិហារកេរ្តិ៍នោះទេ ផ្ទុយទៅវិញ ភាពពិតជាក់ស្ដែងនៃសេចក្ដីថ្លែងនោះទៅវិញទេដែលជាធាតុសំខាន់។ លើសពីនេះ បណ្ដឹងបរិហារកេរ្តិ៍ដែលធ្វើឡើងប្រឆាំងនឹងស្ថាប័នមួយ ជាការផ្ទុយនឹងច្បាប់ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិដែលចែងថារដ្ឋមិនគួរហាមឃាត់ការរិះគន់ស្ថាប័ននោះទេ។[57] ច្បាប់នេះក៏ចែងផងដែរថា "ការកាត់ទោសឱ្យជាប់ពន្ធនាគារមិនមែនជាការពិន័យសមស្រប" ចំពោះបទបរិហារកេរ្តិ៍នោះទេ។[58] ទោះជាយ៉ាងណាក៏ដោយ មាត្រា ៤៣ ចែងថា ក្នុងករណីដែលទង្វើនេះបណ្ដាលឱ្យមាន "គ្រោះថ្នាក់ធ្ងន់ធ្ងរ" ជនល្មើសអាចប្រឈមមុខនឹងការជាប់ពន្ធនាគារពីមួយខែ ទៅប្រាំមួយខែ ហើយការពិន័យសម្រាប់បទចោទប្រកាន់នេះគឺចាប់ពី ពីរលានរៀលទៅ ២០ លានរៀល។ ការដាក់បញ្ចូលការជាប់ពន្ធនាគារទៅក្នុងការផ្ដន្ទាទោសនោះ ក៏មិនស្របនឹងមាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌដែលចែងថា ការបរិហារកេរ្តិ៍គឺត្រូវផ្ដន្ទាទោសដោយការពិន័យជាប្រាក់តែប៉ុណ្ណោះ។ ដូច្នេះហើយ អាចសន្និដ្ឋានបានថា មាត្រា ៤៣ គឺមានគោលបំណងបង្កើនទោសទណ្ឌដែលអាចកើតមានចំពោះបទបរិហារកេរ្តិ៍ ដែលត្រូវបានប្រើប្រាស់ហួសហេតុរួចទៅហើយក្នុងដាក់ទោសទណ្ឌដល់ការអនុវត្តសិទ្ធិ សេរីភាពខាងការបញ្ចេញមតិស្របច្បាប់នៅក្នុងប្រទេសកម្ពុជា។ នេះជារឿងគួរឱ្យព្រួយបារម្ភជាពិសេស ព្រោះថាបច្ចុប្បន្នករណីបរិហារកេរ្តិ៍ភាគច្រើនដែលត្រូវបានគេប្ដឹង។

លើសពីនេះ មាត្រា ៤៤ នៃសេចក្ដីព្រាងច្បាប់បានចែងថា "ការប្រើប្រាស់ភាសាប្រមាថ គ្រប់ពាក្យមើលងាយ ឬគ្រប់ពាក្យទ្រគោះដោយគ្មាន ការទំលាក់កំហុស ទោះលើទង្វើណាមួយតាមបច្ចេកវិទ្យាព័ត៌មាន" នឹងត្រូវពិន័យជាប្រាក់ ហើយក្នុងករណីដែលទង្វើនោះ "បង្កឱ្យកើតមានព្យសនកម្មធ្ងន់ធ្ងរដល់ជនរងគ្រោះ" ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពីមួយខែទៅប្រាំមួយខែ។ ដូច្នេះ ដូចគ្នានឹងមាត្រា ៤៤ គឺមាត្រានេះក៏មិនមានសង្គតិភាពទៅនឹង មាត្រា ៣០៧ នៃក្រមព្រហ្មទណ្ឌកម្ពុជា (បទជេរប្រមាថជាសាធារណៈ) នោះដែរពោលគឺមានតែការពិន័យជាប្រាក់ប៉ុណ្ណោះសម្រាប់ជនល្មើស។ គណៈកម្មាធិការសិទ្ធិមនុស្សបានអះអាងថា មាត្រា ១៩(២) "រួមបញ្ចូលសូម្បីតែការបញ្ចេញមតិដែលអាចចាត់ទុកថាជាការជេរប្រមាថធ្ងន់ធ្ងរ"។[59] ទោះបីជាការបញ្ចេញមតិបែបនេះអាចត្រូវបានរឹតត្បិតក៏ដោយ ការអនុវត្តត្រូវអនុលោមតាមមាត្រា ១៩ (៣) មួយប៉ុណ្ណោះ។ តាមរយៈវិធានការ ភាសាដែលមានលក្ខណៈ "ជេរប្រមាថ" "មើលងាយ" និង "ទ្រគោះ" នឹងត្រូវបានការពារ ។

ការដាក់បញ្ចូលការដាក់ទោសជាប់ពន្ធនាគារសម្រាប់ មាត្រា ៤៣ និងមាត្រា ៤៤ គឺជាការវិវឌ្ឍដ៏គួរឱ្យព្រួយបារម្ភដោយហេតុថាការធ្វើបែបនេះប្រាសចាកពីមាត្រាដែលពាក់ព័ន្ធនៅក្នុងក្រមព្រហ្មទណ្ឌ (៣០៥ និង ៣០៧) និងនាំឱ្យការដាក់ពិន័យសម្រាប់បទចោទប្រកាន់ទាំងនេះកាន់តែធ្ងន់ធ្ងរជាងមុន។ ហេតុដូច្នេះហើយ ការបញ្ចេញមតិតាមរយៈបច្ចេកវិទ្យាព័ត៌មាន ដែលកំណត់បានថាស្ថិតនៅក្រោមបទប្បញ្ញត្តិនៃមាត្រា ៤៣ និង មាត្រា ៤៤ រងនូវការដាក់ពិន័យធ្ងន់ធ្ងរ ដោយហេតុថាការបញ្ចេញមតិនោះធ្វើឡើងតាមរយៈបច្ចេកវិទ្យាព័ត៌មាន។ មូលហេតុនៅពីក្រោយចំណុចនេះនៅតែមិនច្បាស់លាស់ ដូច្នេះហើយនាំឱ្យមានចម្ងល់អំពីចេតនានៅពីក្រោយការដាក់ពិន័យកាន់តែធ្ងន់ធ្ងរដែលមានចែងក្នុងមាត្រាទាំងនេះ និងក្ដីព្រួយបារម្ភពាក់ព័ន្ធនឹងការអនុវត្តតាមអំពើចិត្តដែលអាចកើតមាន។

---

[57] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្ដីពន្យល់ទូទៅលេខ ៣៤ ទ ៣៨
[58] ដូចខាងលើ ទំព័រ៤៧
[59] ដូចខាងលើ ទំព័រ ១១

មាត្រា ៤៩ នៃសេចក្ដីព្រាងច្បាប់បច្ចុប្បន្ន ចែងថា "ការផ្សព្វផ្សាយ ឬការចែកចាយព័ត៌មានមិនពិតតាមបច្ចេកវិទ្យាព័ត៌មាន ដែលមានចេតនាបណ្ដាលឱ្យអន្តរាយដល់វិស័យការពារជាតិ សន្តិសុខជាតិ ទំនាក់ទំនងជាមួយប្រទេសដទៃ សេដ្ឋកិច្ច សណ្ដាប់ធ្នាប់សាធារណៈ ការរើសអើង និងវប្បធម៌ប្រពៃណីជាតិ" ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៣ឆ្នាំ ទៅ ៥ឆ្នាំ។ ការដាក់ជាបទល្មើសព្រហ្មទណ្ឌចំពោះការផ្សព្វផ្សាយព័ត៌មានភាន់ច្រឡំ និងព័ត៌មានក្លែងបន្លំដូចនឹងអ្វីដែលមាត្រាបានកំណត់នោះ គឺមិនស្របនឹងច្បាប់សិទ្ធិមនុស្សឡើយ។[60] ច្បាប់អន្តរជាតិ ដូចដែលបានចែងដោយគណៈកម្មាធិការសិទ្ធិមនុស្ស មិនអនុញ្ញាតឱ្យមានការហាមឃាត់ជាទូទៅចំពោះការបញ្ចេញមតិដែលខុស ឬការបកស្រាយមិនត្រឹមត្រូវអំពីព្រឹត្តិការណ៍ណាមួយឡើយ។[61]

ក្រៅពីផលវិបាកដែលអាចបង្កឡើងដោយបទប្បញ្ញត្តិពាក់ព័ន្ធនឹងសិទ្ធិសេរីភាពខាងការបញ្ចេញមតិទាំងនេះ សេចក្ដីព្រាងច្បាប់ស្ដីពីបទល្មើសបច្ចេកវិទ្យានាពេលបច្ចុប្បន្ន ក៏រួមមានបទប្បញ្ញត្តិដែលអាចរំលោភសិទ្ធិឯកជនភាពផងដែរ។ សិទ្ធិនេះត្រូវបានធានាការពារក្រោមមាត្រា ១២ និង ១៧ នៃសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលចែងថាគ្មានមនុស្សណាម្នាក់ ត្រូវរងការរំលោភជ្រៀតជ្រែកតាមទំនើងចិត្តក្នុងជីវិតឯកជន គ្រួសារ ទីលំនៅ ឬការឆ្លើយឆ្លង ឬការធ្វើឱ្យប៉ះពាល់ ដល់កិត្តិយស និងកេរ្ដិ៍ឈ្មោះរបស់ខ្លួនបានឡើយ។ ជនគ្រប់រូបមានសិទ្ធិទទួលការការពារពីច្បាប់ ប្រឆាំងនឹងការជ្រៀតជ្រែក ឬការប៉ះពាល់បែបនេះ។[62]

មាត្រា ៥ នៃសេចក្ដីព្រាងច្បាប់ស្ដីពីបទល្មើសបច្ចេកវិទ្យាបច្ចុប្បន្នផ្ដល់សិទ្ធិអំណាចធំធេងដល់មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបន្ទុកប្រឆាំងនឹងបទល្មើសបច្ចេកវិទ្យា ដើម្បីស៊ើបអង្កេតបទល្មើសដោយមិនចាំបាច់ជូនដំណឹងដល់តុលាការ។[63] លើសពីនេះ មាត្រា ១២ (១) នៃសេចក្ដីព្រាងច្បាប់បានចែងថា "តាមការស្នើសុំពីអាជ្ញាធរមានសមត្ថកិច្ចក្នុងការប្រមូលភស្ដុតាង ប្រសិនបើមានមូលហេតុសមរម្យ ថាភស្ដុតាងបទល្មើសអាចរកបាននៅលើប្រព័ន្ធកុំព្យូទ័ររបស់អ្នកផ្ដល់សេវា ឬក៏ ក្រោមការគ្រប់គ្រងរបស់អ្នកផ្ដល់សេវា អ្នកផ្ដល់សេវាត្រូវរក្សាទុករាល់ទិន្នន័យកុំព្យូទ័រ ទិន្នន័យចរាចរណ៍ ឬព័ត៌មានពាក់ព័ន្ធរបស់អ្នកប្រើប្រាស់សេវា"។[64] មាត្រាទាំងនេះផ្ដល់សិទ្ធិអំណាចធំធេងដល់មន្ត្រីនគរបាលយុត្តិធម៌ ដែលទទួលបន្ទុកប្រឆាំងនឹងបទល្មើសបច្ចេកវិទ្យា ដើម្បីស៊ើបអង្កេត និងរក្សាទុករាល់ទិន្នន័យដោយមិនចាំបាច់ជូនដំណឹងដល់តុលាការ ឬទទួលការណែនាំពីតុលាការ។ ដូច្នេះហើយ មាត្រានេះរំលោភសិទ្ធិឯកជនភាពរបស់បុគ្គល។

លើសពីនេះទៀត មាត្រា ៧ ផ្ដល់សិទ្ធិអំណាចដល់ក្រសួង ឬស្ថាប័នមានសមត្ថកិច្ចដែលផ្ដល់លិខិតអនុញ្ញាតអាជីវកម្ម អាចព្យួរ ឬដកហូតលិខិតអនុញ្ញាតអាជីវកម្មនោះបាន។[65] មាត្រា ១៨ ក៏ចែងផងដែរថា បុគ្គលណាដែលមិនពេញចិត្តនឹងការព្យួរ ឬការដកហូតលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាប័ណ្ណអាជីវកម្ម ដូចមានចែងក្នុងមាត្រា ៧ នៃច្បាប់នេះ មានសិទ្ធិដាក់ពាក្យបណ្ដឹងទៅកាន់រដ្ឋមន្ត្រីនៃក្រសួង ឬប្រធានស្ថាប័នដែលមានសមត្ថកិច្ច ក្នុងរយៈពេល ៣០ថ្ងៃគិតចាប់ពីថ្ងៃជូនដំណឹងអំពីការសម្រេចចិត្តនេះ។[66]

---

[60] សេចក្ដីប្រកាសរួមស្ដីពីសេរីភាពក្នុងការបញ្ចេញមតិ និង "ព័ត៌មានក្លែងក្លាយ" ព័ត៌មានក្លែងបន្លំ និងការឃោសនា។ អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្ដីពីសេរីភាពក្នុងការបញ្ចេញមតិ និងយោបល់, អ្នកតំណាងនៃ អង្គការសន្តិសុខ និងកិច្ចសហប្រតិបត្តិការរបស់អឺរ៉ុប (OSCE) ស្ដីពីសេរីភាពប្រព័ន្ធផ្សព្វផ្សាយ, អ្នករាយការណ៍ពិសេសស្ដីពីសេរីភាពនៃការបញ្ចេញមតិរបស់គណៈ
កម្មាធិការអន្តរ-អាមេរិកាំងស្ដីពីសិទ្ធិមនុស្ស (InterAmerican Commission on Human Rights) និងអ្នករាយការណ៍ពិសេសស្ដីពីសេរីភាពនៃការបញ្ចេញមតិ និងការទទួលបានព័ត៌មានរបស់គណៈកម្មការអាហ្វ្រិកស្ដីពីសិទ្ធិមនុស្ស និងប្រជាជន (ACHPR) (ឆ្នាំ២០១៧) ទំព័រ២ (ក)
សេចក្ដីរាយការណ៍របស់អ្នករាយការណ៍ពិសេសស្ដីពីការលើកកម្ពស់ និងការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងយោបល់" ឯកសាររបស់អង្គការសហប្រជាជាតិ ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០ ឯកសាររបស់អង្គការសហប្រជាជាតិ A/HRC/៤៤/៤៩ ទ៤៩
[61] គណៈកម្មាធិការសិទ្ធិមនុស្ស (HRC) សេចក្ដីពន្យល់ទូទៅលេខ ៣៤ ទ៤៩
[62] សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស (UDHR) មាត្រា ១២
[63] សេចក្ដីព្រាងច្បាប់ស្ដីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន មាត្រា ៥
[64] សេចក្ដីព្រាងច្បាប់ស្ដីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន មាត្រា ១២
[65] សេចក្ដីព្រាងច្បាប់ស្ដីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន មាត្រា ៧
[66] សេចក្ដីព្រាងច្បាប់ស្ដីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន មាត្រា ១៨



## ខ. សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន

អស់រយៈពេលប្រហែលពីរទសវត្សរ៍មកហើយ ច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានស្ថិតក្នុងដំណើរការរៀបចំសេចក្តីព្រាង ប៉ុន្តែមិនទាន់បញ្ចប់រួចរាល់នៅឡើយទេ។ ដំណើរការរៀបចំរហូតមកដល់បច្ចុប្បន្ននេះមានតម្លាភាព និងបានឆ្លងកាត់ការពិគ្រោះយោបល់ ដែលការណ៍នេះអនុញ្ញាតឱ្យមានការសន្ទនាប្រកបដោយគុណតម្លៃជាមួយអ្នកជំនាញ និងភាគីពាក់ព័ន្ធនានា ហើយក៏បានសម្របសម្រួលសាធារណជនមានការចូលរួម តាមរយៈផតថលអនឡាញផងដែរ។ ក្រុមការងារបច្ចេកទេសទទួលបន្ទុករៀបចំសេចក្តីព្រាងច្បាប់ស្តីពី សិទ្ធិទទួលព័ត៌មានត្រូវបានបង្កើតឡើងដើម្បីសម្របសម្រួលឱ្យមានការចូលរួមពីសំណាក់អ្នកជំនាញ និងភាគីពាក់ព័ន្ធ ដែលរួមមាន តំណាងពីរដ្ឋាភិបាល តំណាងអង្គការសហប្រជាជាតិ និងតំណាងសង្គមស៊ីវិល។ ការណ៍នេះគួរកំណត់ជាបទដ្ឋានសម្រាប់ ច្បាប់ថ្មីទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅពេលរៀបចំសេចក្តីព្រាងច្បាប់ និងពិគ្រោះយោបល់។ គេហទំព័រមួយក៏ត្រូវបានបង្កើតឡើងដើម្បីបង្ហាញអំពីសេចក្តីព្រាងច្បាប់ និងផ្តល់ឱកាសឱ្យសាធារណជនបានបញ្ចេញ មតិយោបល់ផងដែរ ប៉ុន្តែគេហទំព័រនោះមិនបានធ្វើបច្ចុប្បន្នភាពនោះទេ។[67]

បច្ចុប្បន្ននេះ ការទទួលព័ត៌មានត្រូវបានទទួលស្គាល់ថាជាសិទ្ធិមនុស្សជាសកល។ សិទ្ធិនេះមានប្រភពពីសិទ្ធិសេរីភាពខាងការបញ្ចេញមតិ ដែលរាប់បញ្ចូលមិនត្រឹមតែសិទ្ធិក្នុងការ "ចែករំលែក" ព័ត៌មាន និងយោបល់ប៉ុណ្ណោះទេ ប៉ុន្តែក៏រួមមានសិទ្ធិជាសារវន្តក្នុងការ "ស្វែងរក" និង"ទទួល" ព័ត៌មានទាំងនោះផងដែរ។ ការទទួលព័ត៌មាន មិនត្រឹមតែផ្តល់អត្ថប្រយោជន៍ដល់បុគ្គលម្នាក់ៗប៉ុណ្ណោះទេ ប៉ុន្តែក៏ផ្តល់អត្ថប្រយោជន៍ដល់សាធារណជនទូទៅ ក្នុងការលើកកម្ពស់សេរីភាពសារព័ត៌មាន សេរីភាពខាងការបញ្ចេញមតិ និងលទ្ធិប្រជាធិបតេយ្យផងដែរ។ អត្ថប្រយោជន៍មួយចំនួនទៀតនៃការទទួលព័ត៌មានរួមមានជាអាទិ៍៖ លទ្ធិប្រជាធិបតេយ្យដែលមានការចូលរួម ការប្រយុទ្ធប្រឆាំងអំពើពុករលួយ និងកំហុសរបស់រដ្ឋាភិបាល សំដៅជានាបាននូវគណនេយ្យភាពចំពោះការសម្រេចចិត្ត និងអ្នកបង្កើតគោលនយោបាយ សេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាព ការសម្របសម្រួលឱ្យមានការសម្រេចចិត្តដែលមានព័ត៌មានគ្រប់គ្រាន់ និងការលើកកម្ពស់ការគោរពសិទ្ធិមនុស្ស។

ទោះបីមានដំណើរការប្រកបដោយការលើកទឹកចិត្តក្នុងការរៀបចំសេចក្តីព្រាងច្បាប់ក៏ដោយ ក្នុងនោះនៅតែមានបទប្បញ្ញត្តិជាច្រើនមិនទាន់ស្របគ្នាទៅនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។

[67] ក្រាហ្វិកព័ត៌មានរបស់ម.ស.ម.ក ស្តីពីការទទួលព័ត៌មាននៅកម្ពុជា រកមើលបាននៅ៖ https://cchrcambodia.org/en/publications/infographics/access-to-information-in-cambodia-148

មាត្រា ៤ នៃសេចក្ដីព្រាងច្បាប់នេះមាននូវពាក្យបច្ចេកទេសពាក់ព័ន្ធ រួមទាំង "ឯកសារផ្លូវការ" ដែលជាពាក្យមិនច្បាស់លាស់ និងផ្អែកលើការយល់រៀងៗខ្លួន និងមិនបានផ្ដល់ការពន្យល់ច្បាស់លាស់នោះទេ ដូច្នេះហើយ កត្តានេះអាចរឹតត្បិតទៅលើវិសាលភាពនៃការទទួលបានព័ត៌មានដែលត្រូវបានអនុញ្ញាត។

មាត្រា ២០ នៃសេចក្ដីព្រាងច្បាប់នេះរៀបរាប់អំពីព័ត៌មានសម្ងាត់ដែលមិនអាចបង្ហាញជាសាធារណៈបាន។ ទោះបីយ៉ាងណា មាត្រានេះមិនបានបញ្ជាក់ច្បាស់អំពីចំណុចពិចារណាថាតើការបញ្ចេញព័ត៌មាននេះអាចបង្កផលប៉ះពាល់ធ្ងន់ធ្ងរឬយ៉ាងណាឡើយ។ លើសពីនេះទៅទៀត មាត្រា ២០ (៧) ដែលហាមមិនឱ្យបង្ហាញ "ព័ត៌មាន សម្ងាត់ផ្សេងទៀតដូចដែលមានចែងក្នុងបញ្ញត្តិហាមឃាត់" នោះអាចត្រូវបានយកទៅប្រើជាបញ្ញត្តិដែលមានន័យទូលាយដើម្បីប្រើជាមូលហេតុក្នុងការដកសិទ្ធិទទួលព័ត៌មានដើម្បីផលប្រយោជន៍សាធារណៈ ប៉ុន្តែរដ្ឋាភិបាល ឬសមាជិករដ្ឋាភិបាលអាចចាត់ទុកថាប៉ះពាល់ដល់កេរ្ដិ៍ឈ្មោះជាសាធារណៈរបស់ខ្លួន។[68]

ដើម្បីបំពេញតាមបទដ្ឋានអន្តរជាតិ ការលើកលែងត្រូវមានលក្ខណៈច្បាស់លាស់ មិនមានភាពស្រពិចស្រពិល និងមានវិសាលភាពតូចចង្អៀត។ បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិចែងថា ការមិនបង្ហាញព័ត៌មានត្រូវតែមានមូលហេតុត្រឹមត្រូវទៅតាមករណីនីមួយៗ ហើយការលើកលែងអាចអនុវត្តបានលុះត្រាតែ "មានហានិភ័យនៃគ្រោះថ្នាក់ធ្ងន់ធ្ងរចំពោះផលប្រយោជន៍ដែលត្រូវបានការពារ ហើយដែលគ្រោះថ្នាក់នោះធំជាងផលប្រយោជន៍សាធារណៈទាំងមូលក្នុងការទទួលព័ត៌មាន"។[69]

តាមរយៈវិធាននេះ មាត្រា ២០.៧ មានលក្ខណៈទូលំទូលាយពេក ខ្វះភាពជាក់លាក់ ហេតុដូច្នេះអាចនឹងត្រូវបានចាត់ទុកថាជាបទប្បញ្ញត្តិទូទៅ។ លើសពីនេះ មាត្រានេះមិនមាន "ការធ្វើថ្លឹងថ្លែងបីផ្នែក" ដើម្បីកំណត់ថាតើព័ត៌មានដែលត្រូវបានលើកលែងអាចត្រូវបានបិទបាំងពីសាធារណជនដែរឬទេ។ បទដ្ឋានអន្តរជាតិនៃការទទួលបានព័ត៌មានតម្រូវឱ្យមានការអនុវត្តការធ្វើតេស្តបូកសរុបបីផ្នែកទាក់ទងនឹងសេរីភាពខាងការបញ្ចេញមតិដែលមានដូចជា៖ តើការលើកលែងនេះចែងនៅក្នុងច្បាប់ដែរឬទេ ដែលប្រកាន់ខ្ជាប់នូវគោលការណ៍នៃភាពប្រាកដ ប្រជាផ្អែកច្បាប់ដែរឬទេ? តើការលើកលែងនេះបម្រើគោលបំណងស្របច្បាប់មួយក្នុងចំណោមគោលបំណង ស្របច្បាប់ដែលមានចែងក្នុងមាត្រា ១៩(៣) ដែរឬទេ? ហើយស្របតាមគោលការណ៍នៃភាពចាំបាច់ និងសមាមាត្រ តើការលើកលែងនោះចាំបាច់និងតម្រូវឱ្យមានមធ្យោបាយដែលមានការរឹតត្បិតតិចបំផុត ដើម្បីសម្រេចបាននូវគោលបំណងដែលបានអះអាងដែរឬទេ?[70]

មាត្រា ២៦ នៃសេចក្ដីព្រាងច្បាប់មិនបានផ្ដល់ការការពារដល់អ្នកបង្ហាញព័ត៌មាន ដែលគួរតែត្រូវបានបន្ថែមទៅក្នុងមាត្រានេះ ប្រសិនបើការបង្ហាញព័ត៌មាននោះគឺដើម្បីផលប្រយោជន៍សាធារណៈ។ លើសពីនេះ មាត្រា ៣៣ នៃសេចក្ដីព្រាងច្បាប់ក៏បានកំណត់ទោសព្រហ្មទណ្ឌជាប់ពន្ធនាគារដែលមិនស្របផងដែរ។

---

[68] សេចក្ដីព្រាងច្បាប់ស្ដីពីសិទ្ធិទទួលព័ត៌មាន មាត្រា ២០។

[69] UNGA, របាយការណ៍របស់អ្នករាយការណ៍ពិសេសស្ដីពីសេរីភាពនៃមតិយោបល់ និងមតិ, A/68/362,ទំព័រ៧៦ https://tinyurl.com/UNSR-FreedEx-2013-A2I

[70] គណៈកម្មការសិទ្ធិមនុស្ស, សេចក្ដីអធិប្បាយទូទៅលេខ. ៣៤, ៜ២២,UNGA, A/68/362, §76

## គ. សេចក្តីព្រាងច្បាប់ស្តីពីសន្តិសុខសាយប័រ

ខែវិច្ឆិកា ឆ្នាំ ២០២២ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ របស់កម្ពុជាបានប្រកាសថា ខ្លួនបានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីសន្តិសុខសាយប័រក្នុងគោលបំណងដើម្បីកំណត់ "គោលការណ៍ វិធាន និងយន្តការដើម្បីគ្រប់គ្រង និងរក្សាសន្តិសុខសាយប័រនៃហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ក្នុងគោលបំណងធានានូវសេវាសារវន្តរបស់ជាតិប្រកបដោយសុវត្ថិភាព និងនិរន្តរភាព។[71] ចាប់តាំងពីពេលនោះមក ក្រសួងបាននឹងកំពុងពិនិត្យមើលឡើងវិញ ហើយកែសម្រួលសេចក្តីព្រាងច្បាប់នេះស្របតាមធាតុចូលពីភាគីពាក់ព័ន្ធ។ ទោះជាយ៉ាងនេះក្តី សេចក្តីព្រាងច្បាប់បច្ចុប្បន្នទំនងជាមានផលប៉ះពាល់អវិជ្ជមានដល់សិទ្ធិឯកជនភាព និងសេរីភាពខាងការបញ្ចេញមតិ ព្រមទាំងសិទ្ធិទទួលព័ត៌មានផងដែរ។

មាត្រា ៤ នៃសេចក្តីព្រាងច្បាប់នេះផ្តល់អំណាចទូលំទូលាយដល់គណៈកម្មាធិការសន្តិសុខឌីជីថល (គ.ស.ឌ.) ជាស្ថាប័នប្រតិបត្តិមានការសម្របសម្រួលដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ដែលមានភារកិច្ចធានានូវប្រសិទ្ធភាព និងប្រសិទ្ធផលនៃការបំពេញមុខងារក្នុងការដឹកនាំសម្របសម្រួល និងជំរុញការគ្រប់គ្រងសន្តិសុខឌីជីថល"។[72] អំណាចគួរឱ្យបារម្ភបំផុតមួយចំនួនដែលផ្តល់ទៅឱ្យ គ.ស.ឌ. រួមមានសិទ្ធិអំណាចក្នុងការបញ្ជាឱ្យអង្គការឯកជនមួយដើម្បី៖ "ផ្តល់ព័ត៌មាន ហើយអនុញ្ញាតឱ្យប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកដែលពាក់ព័ន្ធ" ដោយមានការយល់ព្រមពីអង្គការឯកជន ក្នុងគោលបំណងបង្ការទប់ស្កាត់ ដោះស្រាយ និងកាត់បន្ថយហានិភ័យដែលបណ្តាលមកពីការគំរាមកំហែង ឬឧប្បត្តិហេតុសន្តិសុខសាយប័រ[73] "ដើម្បីអនុញ្ញាតឱ្យមន្ត្រីទទួលបន្ទុក គ.ស.ឌ. ចូលប្រើកុំព្យូទ័រ ឬប្រព័ន្ធកុំព្យូទ័រដែលពាក់ព័ន្ធណាមួយ" ដែលអង្គការឯកជនមិនអាចទប់ស្កាត់ ព្រមទាំងកាត់បន្ថយឧប្បត្តិហេតុសន្តិសុខសាយប័រដែលបានឈានដល់ "កម្រិតធ្ងន់ធ្ងរ"[74] និង "ចូលប្រើទិន្នន័យកុំព្យូទ័រ ឬទិន្នន័យ ផ្សេងទៀត" យោងតាមដីកាតុលាការក្នុងស្ថានភាពដែលអង្គការឯកជនមិនអាចបញ្ចប់ ឬកាត់បន្ថយផលប៉ះពាល់ ដែលបណ្តាលមកពីការគំរាមកំហែងចំពោះសន្តិសុខសាយប័រ។[75] អំណាចសំខាន់ៗទាំងនេះដែលបានផ្តល់ឱ្យ គ.ស.ឌ. មានវិសាលភាពច្រើនពេក ហើយមិនអនុលោមតាមគោលការណ៍នីត្យានុកូលភាព និងសមាមាត្រ នៃមាត្រា ១៩ ក.អ.ស.ព.ន នោះទេ។ យោងតាមមាត្រា ១៩ និង ២១ នៃសេចក្តីព្រាងច្បាប់នេះ គ.ស.ឌ. មិនត្រូវបានតម្រូវឱ្យទទួលបានការអនុម័តជាមុនពីអាជ្ញាធរតុលាការ ឬស្ថាប័នត្រួតពិនិត្យ មុនពេលចេញបញ្ជាណាមួយដើម្បី "ផ្តល់ព័ត៌មាន ហើយអនុញ្ញាតឱ្យប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកដែលពាក់ព័ន្ធ" ឬអនុញ្ញាតឱ្យចូលប្រើ "កុំព្យូទ័រ ឬប្រព័ន្ធកុំព្យូទ័រដែលពាក់ព័ន្ធណាមួយ"។ កត្តានេះផ្ទុយនឹងគោលការណ៍នីត្យានុកូលភាពដែលតម្រូវឱ្យវិធានការណាមួយ ដែលអាចជ្រៀតជ្រែកសិទ្ធិឯកជនភាព និងសេរីភាពក្នុងការបញ្ចេញមតិរបស់បុគ្គលម្នាក់ ត្រូវតែយកមកអនុវត្តដោយមានការការពារដ៏រឹងមាំពីតុលាការ។

---

[71] សេចក្តីព្រាងច្បាប់ស្តីពីសន្តិសុខសាយប័រ មាត្រា ១
[72] សេចក្តីព្រាងច្បាប់ស្តីពីសន្តិសុខសាយប័រ មាត្រា ៤
[73] សេចក្តីព្រាងច្បាប់ស្តីពីសន្តិសុខសាយប័រ មាត្រា ១៩
[74] សេចក្តីព្រាងច្បាប់ស្តីពីសន្តិសុខសាយប័រ មាត្រា ២១
[75] សេចក្តីព្រាងច្បាប់ស្តីពីសន្តិសុខសាយប័រ មាត្រា ២២

មាត្រា ២១ (១) នៃសេចក្តីព្រាងច្បាប់នេះដែលអនុញ្ញាតឱ្យ គ.ស.ឌ. ចូលប្រើ "កុំព្យូទ័រ ឬប្រព័ន្ធកុំព្យូទ័រដែលពាក់ព័ន្ធណាមួយ" អាចប៉ះពាល់ដល់សិទ្ធិឯកជនភាព ដោយសារមាត្រា ២១ (១) មិនបញ្ជាក់ថា គ.ស.ឌ. នឹងកំណត់គោលដៅទិន្នន័យដែលចាំបាច់ ដើម្បីបង្ការ "ការគំរាមកំហែងចំពោះសន្តិសុខសាយប័រ"។ មាត្រា ២១ (១) ក៏ហាក់ដូចមិនមែនជាវិធានការរំខានតិចតួចបំផុតដែលមានសម្រាប់ការកម្រិតគោលបំណងនោះផងដែរ ស្របតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។[76] ការរៀបចំពាក្យពេចន៍ទូលំទូលាយនេះអាចអនុញ្ញាតឱ្យ គ.ស.ឌ. ចូលប្រើទិន្នន័យឯកជនដែលបានរក្សាទុកក្នុងប្រព័ន្ធកុំព្យូទ័របានយ៉ាងល្អលើសពីអ្វីដែលត្រូវបានតម្រូវសម្រាប់ស្ថានការណ៍ដែលកំពុងពិភាក្សា។ បញ្ញត្តិមិនគ្រប់គ្រាន់នៅក្នុងសេចក្តីព្រាងដើម្បីបង្កើតយន្តការត្រួតពិនិត្យសម្រាប់ គ.ស.ឌ. ធ្វើឱ្យក្តីកង្វល់នេះកាន់តែកើនឡើងខ្លាំងអំពីការចូលប្រើប្រាស់ទិន្នន័យឯកជនហួសកម្រិតដែលផ្តល់ឱ្យ គ.ស.ឌ.។

មាត្រា ២៤ បង្កើតមន្ត្រីអធិការកិច្ចសន្តិសុខសាយប័រ ដែលត្រូវបានជ្រើសតាំងជា "មន្ត្រីនគរបាលយុត្តិធម៌" ដោយរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដើម្បី "តាមដាន ស្រាវជ្រាវ ត្រួតពិនិត្យ និងជំរុញការអនុវត្តច្បាប់នេះ"។ មន្ត្រីអធិការកិច្ចទាំងនេះត្រូវបានផ្តល់អំណាចទូលំទូលាយពេកដែលអាចជ្រៀតជ្រែកសិទ្ធិឯកជនភាព សេរីភាពខាងការបញ្ចេញមតិ និងសិទ្ធិទទួលព័ត៌មាន។ អំណាចទាំងនេះរួមមានសមត្ថភាពក្នុងការ "ស្រាវជ្រាវ សង្កេត តាមដាន ទប់ស្កាត់ និងឆ្លើយតបទៅនឹងការគំរាមកំហែងសន្តិសុខសាយប័រ និងឧប្បត្តិហេតុ [...]" (មាត្រា ២៦) និង "ឆែកឆេរ ចាប់យកវត្ថុតាង កោះហៅបុគ្គលពាក់ព័ន្ធ ហើយបំពេញកិច្ចនីតិវិធីដទៃទៀតស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ" (មាត្រា ២៧)។ មាត្រា ២៤ មិនបញ្ជាក់ច្បាស់នូវវិធានការដាក់លាក់ដែលមន្ត្រីអធិការកិច្ចសន្តិសុខសាយប័រត្រូវបានអនុញ្ញាតឱ្យអនុវត្តមុខងារទាំងនេះឡើយ ដូច្នេះហើយអនុញ្ញាតឱ្យមន្ត្រីអធិការកិច្ចចាត់វិធានការទៅតាមការចង់បាន។



## ឃ.សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារទិន្នន័យបុគ្គលនៃព្រះរាជាណាចក្រកម្ពុជា

នៅថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ ២០២១ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានប្រកាសថាខ្លួននឹងចាប់ផ្តើមដំណើរការសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារទិន្នន័យបុគ្គល។ បន្ទាប់មកក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានចែកសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារទិន្នន័យបុគ្គលដល់សម្រាប់អង្គការ និងក្រុមហ៊ុនឯកជនមួយចំនួនកាលពីខែកញ្ញា ឆ្នាំ២០២៣ ដើម្បីទទួលបានមតិយោបល់ទៅលើសេចក្តីព្រាងនេះ។ ការចាប់ផ្តើមដំណើរការនេះបានកើតឡើងចំពេលដែលបណ្តាប្រទេសជុំវិញពិភពលោកកំពុងកែសម្រួល ឬធ្វើសេចក្តីព្រាងច្បាប់ការពារទិន្នន័យរៀងៗខ្លួន ដោយមើលឃើញនៅក្នុងពិភពលោកដែលធ្វើឌីជីថលតូបនីយកម្មខ្លាំងឡើងៗ ទិន្នន័យកាន់តែច្រើនកំពុងត្រូវបានប្រមូល ចែករំលែក និងរក្សាទុកជាងពេលមុន ដែលនាំមកនូវកង្វល់ពាក់ព័ន្ធនឹងឯកជនភាព។ នៅខែមិថុនា ឆ្នាំ ២០២៥ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានចេញសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារទិន្នន័យបុគ្គលដែលបានកែប្រែ ("សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារទិន្នន័យបុគ្គល")។ គោលបំណងនៃសេចក្តីព្រាងច្បាប់នេះ គឺដើម្បីធ្វើនិយ័តកម្មលើដំណើរការ (រួមមានការប្រមូល ការប្រើប្រាស់ និងការបង្ហាញ) ទិន្នន័យផ្ទាល់ខ្លួន និងដើម្បីការពារសិទ្ធិឯកជនភាពរបស់រូបវន្តបុគ្គលនៅប្រទេសកម្ពុជា។

---

[76] គណៈកម្មការសិទ្ធិមនុស្ស,ក.អ.ស.ព.ន/C/GC/៣៤ ទំព័រ៣៤

សិទ្ធិឯកជនភាពត្រូវបានធានាតាមមាត្រា ៤០ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា។ សិទ្ធិឯកជនភាពត្រូវក៏ត្រូវបានការពារក្រោមក្រមរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌផងដែរ។ នៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ សិទ្ធិឯកជនភាពត្រូវបានធានាដោយមាត្រា ១៧ នៃ ក.អ.ស.ព.ន. ដែលត្រូវបានផ្តល់សច្ចាប័ន ដោយប្រទេសកម្ពុជាក្នុងឆ្នាំ ១៩៩២។ មាត្រា ១៧ ចែងថា "គ្មាននរណាម្នាក់ត្រូវទទួលរងនូវការជ្រៀតជ្រែកតាមទំនើងចិត្ត ឬដោយខុសច្បាប់ចំពោះឯកជនភាព គ្រួសារ ផ្ទះសម្បែង ឬការឆ្លើយឆ្លងរបស់គាត់" ហើយ "មនុស្សគ្រប់រូបមានសិទ្ធិទទួលបានការការពារពីច្បាប់ប្រឆាំងនឹងការជ្រៀតជ្រែកនេះ"។

ការរឹតត្បិតលើការអនុវត្តសិទ្ធិឯកជនភាពត្រូវតែស្របតាមបទដ្ឋានភាពស្របច្បាប់និងភាពចាំបាច់ មានន័យថា សមត្ថភាពរបស់រដ្ឋាភិបាលក្នុងការជ្រៀតជ្រែកសិទ្ធិឯកជនភាពរបស់បុគ្គលត្រូវតែសមាមាត្រផងដែរ ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងគោលបំណងសមស្របផង។[77] ការតាមដានរបស់រដ្ឋាភិបាល ដែលមានវិសាលភាពទូលំទូលាយគ្មានដែនកំណត់ ឬធ្វើឡើងដោយសម្ងាត់ គឺជាការរំលោភលើច្បាប់សិទ្ធិមនុស្ស អន្តរជាតិ។ គណៈកម្មាធិការសិទ្ធិមនុស្សបានចែងថា មាត្រា ១៧ តម្រូវឱ្យរដ្ឋបង្កើតក្របខ័ណ្ឌច្បាប់ដែលហាមឃាត់ការរំលោភលើសិទ្ធិឯកជនដោយបុគ្គលឯកជន និងអង្គភាព ក៏ដូចជាការការពារសិទ្ធិ។

គណៈកម្មាធិការសិទ្ធិមនុស្សចែងបន្ថែមទៀតថា បុគ្គលគ្រប់រូបមានសិទ្ធិដឹងថា "ទិន្នន័យផ្ទាល់ខ្លួនអ្វីខ្លះដែលត្រូវបានរក្សាទុកក្នុងឯកសារទិន្នន័យដោយស្វ័យប្រវត្តិ និងសម្រាប់គោលបំណងអ្វីខ្លះ" "អាចដឹងប្រាកដថា អាជ្ញាធរសាធារណៈ ឬបុគ្គលឯកជន ឬស្ថាប័នមួយណាដែលគ្រប់គ្រង ឬអាចគ្រប់គ្រងឯកសាររបស់ពួកគេ" និង "សិទ្ធិស្នើសុំកែតម្រូវ ឬលុបចោល"។

គោលការណ៍ទាំងនេះដែលគូសបញ្ជាក់ដោយគណៈកម្មាធិការសិទ្ធិមនុស្ស ដូចជាសិទ្ធិទទួលព័ត៌មាន សិទ្ធិចូលប្រើប្រាស់ សិទ្ធិកែតម្រូវ និងសិទ្ធិក្នុងការលុបបំបាត់ ឬ ("សិទ្ធិបំភ្លេចចោល") បង្កើតជាមូលដ្ឋានសម្រាប់ច្បាប់ស្តីពីកិច្ចការពារទិន្នន័យជាច្រើន។ បទប្បញ្ញត្តិការពារទិន្នន័យទូទៅរបស់សហភាពអឺរ៉ុបគឺជាឧទាហរណ៍មួយ ហើយជាឯកសារគោលសម្រាប់ច្បាប់ស្តីពីកិច្ចការពារទិន្នន័យជាច្រើនទៀតនៅជុំវិញពិភពលោក ដូចជាច្បាប់ស្តីពីកិច្ចការពារទិន្នន័យរបស់ប្រទេសប្រេស៊ីល និងចក្រភពអង់គ្លេសជាដើម។

ទោះបីច្បាប់ស្តីពីកិច្ចការពារទិន្នន័យរួមបញ្ចូលជាចម្បងនូវសិទ្ធិឯកជនភាពក៏ដោយ ក៏វាប៉ះពាល់ដល់សិទ្ធិខាងការបញ្ចេញមតិផងដែរ ជាពិសេសនៅពេលដែលសិទ្ធិនោះត្រូវបានអនុវត្តលើអនឡាញ ឬជាទម្រង់ឌីជីថល ដោយសារវាអាចមានអានុភាពរារាំង ឬត្រួតពិនិត្យលើបុគ្គលនានា។ ដូចដែលបានអះអាងដោយគណៈកម្មាធិការសិទ្ធិមនុស្សថា បុគ្គលដែលមានមូលហេតុភ័យខ្លាចថា ការទំនាក់ទំនងរបស់ពួកគេអាចត្រូវរដ្ឋាភិបាលតាមដាន ដូច្នេះបុគ្គលទំនងជាមិនសូវបញ្ចេញមតិនោះទេដោយសារតែការភ័យខ្លាច។[78]

[77] ក.អ.ស.ព.ន. មាត្រា ១៩

[78] គណៈកម្មការសិទ្ធិមនុស្ស,ក.អ.ស.ព.ន/C/GC/៣៤ ទំព័រ៣-៤

ម.ស.ម.ក បានវាយតម្លៃលើបញ្ញត្តិជាវិជ្ជមានមួយចំនួននៃសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារទិន្នន័យបុគ្គល ដូចជា បញ្ញត្តិដែលអនុញ្ញាតឱ្យស្ថាប័នមិនស្វែងរកប្រាក់ចំណេញដំណើរការទិន្នន័យផ្ទាល់ខ្លួនដ៏រសើបនៃប្រធានទិន្នន័យនៅពេលធ្វើដូច្នេះជាផ្នែកនៃដំណើរការការងារធម្មតា និងដោយមានការការពារ មាត្រា ១៤ (ឃ)។ ការលុបចោលលក្ខខណ្ឌតម្រូវដែលអ្នកត្រួតពិនិត្យទិន្នន័យរក្សាទុកទិន្នន័យផ្ទាល់ខ្លួន ដែលប្រមូលបានទាំងអស់នៅកម្ពុជា មាត្រា ២៣ ស្របតាមឧត្តមានុវត្តអន្តរជាតិ។ ទោះបី ម.ស.ម.ក ស្វាគមន៍ចំពោះបញ្ញត្តិទាំងនេះក៏ដោយ ក៏ការវិភាគរបស់ ម.ស.ម.ក បានបង្ហាញពីទិដ្ឋភាពនៃបញ្ហាមួយចំនួននៃសេចក្តីព្រាងបច្ចុប្បន្នផងដែរ។ មានន័យថាសេចក្តីព្រាងនេះខ្វះភាពច្បាស់លាស់ពាក់ព័ន្ធនឹងករណីលើកលែងចំពោះលក្ខខណ្ឌតម្រូវដំណើរការទិន្នន័យ ដំណើរការទិន្នន័យដោយគ្មានការយល់ព្រមពីបុគ្គល និងកង្វះសិទ្ធិការពារទិន្នន័យឯករាជ្យ។ បញ្ហាទាំងនេះភាគច្រើនមាននៅក្នុងមាត្រា ៧ មាត្រា១៤ និង មាត្រា៤ នៃសេចក្តីព្រាងបច្ចុប្បន្ន។

## មាត្រា ៧

មាត្រា ៧ នៃសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារទិន្នន័យបុគ្គល គ្របដណ្តប់លើមូលដ្ឋានច្បាប់សម្រាប់ដំណើរការទិន្នន័យផ្ទាល់ខ្លួន។ មាត្រា ៧ ចែងថា ការដំណើរការទិន្នន័យបុគ្គលផ្អែកលើមូលដ្ឋានគតិយុត្តណាមួយដូចខាងក្រោម៖

ក. ការយល់ព្រមពីប្រធានទិន្នន័យ។
ខ. ភាពចាំបាច់នៃការអនុវត្តកិច្ចសន្យាដែលប្រធានទិន្នន័យជាភាគីនៃកិច្ចសន្យា ឬតាមសំណើរបស់ប្រធានទិន្នន័យ មុនពេលបង្កើតកិច្ចសន្យា។
គ. ភាពចាំបាច់នៃរបស់បុគ្គលគ្រប់គ្រងទិន្ន័យដែលត្រូវអនុវត្តកាតព្វកិច្ចតាមច្បាប់។
ឃ. ភាពចាំបាច់សម្រាប់ការពារអាយុជីវិតប្រធានទិន្ន័យ ឬរូបវន្តបុគ្គលផ្សេងទៀត។
ង. ភាពចាំបាច់សម្រាប់គោលបំណងនៃការបំពេញភារកិច្ចក្នុងផលប្រយោជន៍សាធារណៈ។
ច. ភាពចាំបាច់សម្រាប់សម្រាប់គោលបំណងនៃផលប្រយោជន៍ស្របធម្មានុរូបរបស់បុគ្គលគ្រប់គ្រងទិន្ន័យ ឬតតិយជន។

មាត្រាដែលចំណុចកង្វល់ដ៏ធំនៃមាត្រា៧គឺចំនុច (ឃ) (ង) និង (ច) ដោយសារអេង្គហេតុដែលថា ករណីលើកលែងទាំងនេះត្រូវបានប្រើពាក្យទូលំទូលាយ ដូច្នេះហើយទុកចន្លោះប្រហោងម្រាប់ការអនុវត្តតាមទំនើងចិត្ត។ យោងតាមមាត្រានេះ ទិន្នន័យរបស់បុគ្គលអាចត្រូវបានដំណើរការដោយគ្មានការយល់ព្រមពីពួកគេ ដោយសារពាក្យ "ផលប្រយោជន៍សាធារណៈ" "ផលប្រយោជន៍ស្របច្បាប់" ឬ "ផលប្រយោជន៍សំខាន់ៗរបស់...រូបវន្តបុគ្គលផ្សេងទៀត" មិនត្រូវបានកំណត់ឱ្យបានច្បាស់លាស់។ ទោះបីបញ្ជីពេញលេញ ឬនិយមន័យទាំងអស់ដែលអាចតម្រូវឱ្យមានករណីលើកលែងក៏ដោយ ក៏ឧត្តមានុវត្តស្តីពីបញ្ហានេះត្រូវបានបង្ហាញឱ្យឃើញនៅក្នុងបទប្បញ្ញត្តិការពារទិន្នន័យទូទៅរបស់សហភាពអឺរ៉ុបនិងបទប្បញ្ញត្តិការពារទិន្នន័យទូទៅរបស់ចក្រភពអង់គ្លេសដូចដែលបានផ្តល់នូវឧទាហរណ៍ "ផលប្រយោជន៍ស្របច្បាប់" (ទីផ្សា ការបង្ការការឆបោក សន្តិសុខព័ត៌មានវិទ្យាដែលបង្ហាញពីអំពើឧក្រិដ្ឋកម្ម ឬការគំរាមកំហែងដែលអាចកើតមានចំពោះសន្តិសុខសាធារណៈ ដែលជានានូវបណ្តាញ និងសន្តិសុខព័ត៌មាន និង "លក្ខខណ្ឌផលប្រយោជន៍ សាធារណៈ" ដែលបានកំណត់យ៉ាងចង្អៀត កំណត់បញ្ជីមានឧទាហរណ៍ចំនួន ២៣ "ដែលបានកំណត់យ៉ាងចង្អៀត"។[79] ដូច្នេះ ករណីលើកលែងទូលំទូលាយទាំងនេះនៅក្រោមមាត្រា ៧ (ឃ) (ង) និង (ច) មិន

[79] ICO, តើអ្វីជាលក្ខណ្ឌនៃផលប្រយោជន៍សាធារណៈ? https://ico.org.uk/for-organisations/uk-gdpr-guidance-and-resources/lawful-basis/special-category-data/what-are-the-substantial-public-interest-conditions/

បំពេញតាមលក្ខខណ្ឌតម្រូវផ្នែកច្បាប់នៅក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិនោះទេ ដោយសារករណីលើកលែងទាំងនេះមិនត្រូវបានរៀបចំពាក្យពេចន៍ឱ្យបានច្បាស់លាស់គ្រប់គ្រាន់ ដូច្នេះផ្តល់ឆន្ទានុសិទ្ធិទូលំទូលាយអំពីការអនុវត្តករណីលើកលែងទាំងនេះដល់បុគ្គលត្រួតពិនិត្យទិន្នន័យ ។

**មាត្រា ១៤**

មាត្រា ១៤ នៃសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារទិន្នន័យបុគ្គលគ្របដណ្តប់លើការការពារទិន្នន័យផ្ទាល់ខ្លួនដ៏រសើប។ មាត្រា ១៤ ហាមឃាត់ការដំណើរការ "ទិន្នន័យផ្ទាល់ខ្លួនដ៏រសើប" (ទិន្នន័យវេជ្ជសាស្ត្រ ទិន្នន័យហិរញ្ញវត្ថុ ទិន្នន័យរបស់កុមារ ឬអត្តសញ្ញាណផ្ទាល់ខ្លួន គឺលិខិតឆ្លងដែនក្តី ឬអត្តសញ្ញាណប័ណ្ណជាតិក្តី)។ ទោះបីយ៉ាងណា ក៏មាត្រា ១៤ កំណត់នូវសេណារីយ៉ូចំនួន៩ ដែលសេណារីយ៉ូនេះ ករណីលើកលែងអាចត្រូវបានធ្វើឡើងចំពោះការហាមឃាត់ បន្ថែមពីលើមូលដ្ឋានច្បាប់មួយក្នុងចំណោមមូលដ្ឋានច្បាប់នានា យោងតាមមាត្រា ៧។

ស្រដៀងគ្នាទៅនឹងមាត្រា ៧ (ឃ) មាត្រា ១៤ (គ) សំដៅទៅលើ "ផលប្រយោជន៍សំខាន់" ជាករណីលើកលែងដែលអាចកើតមាន ប៉ុន្តែមាត្រា ១៤ មិនបានបញ្ជាក់ច្បាស់អំពីអ្វីដែលអាចជាផលប្រយោជន៍សំខាន់ទាំងនេះ។ នេះក៏ជាករណីសម្រាប់មាត្រា ១៤(ឆ) ដែលលើកឡើងអំពី "ផលប្រយោជន៍សាធារណៈ" ដោយមិនមានការលម្អិតច្បាស់លាស់អំពីអ្វីដែលផលប្រយោជន៍សាធារណៈអាចនាំមកនូវការចាំបាច់។

មាត្រា ១៤ (ង) ក៏ជាកង្វល់ផងដែរពាក់ព័ន្ធនឹងការដំណើរការទិន្នន័យដោយគ្មានការយល់ព្រមដែរ ដោយសារមាត្រា ១៤ ចែងថា ទិន្នន័យរសើបអាចត្រូវបានដំណើរការនៅពេលដែលទិន្នន័យ "ត្រូវបានបង្ហាញជាសាធារណៈជាក់ស្តែងដោយប្រធានទិន្នន័យ"។ ករណីលើកលែងនេះតម្រូវឱ្យមានការបកស្រាយដ៏ចង្អៀតសម្រាប់ការអនុវត្ត ជាពិសេសពាក់ព័ន្ធនឹងទិន្នន័យផ្ទាល់ខ្លួនដែលមានតាមរយៈបណ្តាញទំនាក់ទំនងសង្គម។ ដូចដែលបានសង្ខេបដោយមជ្ឈមណ្ឌលអន្តរជាតិសម្រាប់ច្បាប់មិនរកផលចំណេញ (ICNL) ក្នុងការវិភាគលើសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារទិន្នន័យបុគ្គល "អ្នកប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គមដែលបង្ហោះអំពីគំនិតនយោបាយ ជំនឿ ឬព័ត៌មានរសើបផ្សេងទៀតរបស់ពួកគេក្នុងចេតនាចែករំលែកជាមួយមិត្តភក្តិ និងគ្រួសាររបស់ពួកគេ អាចមិនដឹងថា ព័ត៌មានរបស់ពួកគេមានជាសាធារណៈ និងអាចចូលប្រើបានសម្រាប់ភាគីទីបីដើម្បីដំណើរការតាមរបៀបដែលពួកគេមិនមានចេតនា។ ការដំណើរការ ទិន្នន័យនោះនឹងមិនត្រូវនឹងកម្មវត្ថុ និងគោលបំណងនៃច្បាប់ស្តីពីកិច្ចការពារទិន្នន័យ"។[80]

ដូច្នេះ ម.ស.ម.ក សូមផ្តល់អនុសាសន៍ឱ្យកែសម្រួលមាត្រានេះ ដើម្បីបញ្ជាក់ឱ្យច្បាស់ថា ទិន្នន័យដែលមានជាសាធារណៈមិនរួមបញ្ចូលទិន្នន័យដែលត្រូវបានផ្សព្វផ្សាយនៅលើបណ្តាញទំនាក់ទំនងសង្គម ហើយមានន័យថាមានតែទិន្នន័យដែល ប្រធានទិន្នន័យបានបង្ហាញជាសាធារណៈដោយចេតនាប៉ុណ្ណោះ។

[80] ICNL, សេចក្តីព្រាងច្បាប់ស្តីពីការការពារទិន្នន័យផ្ទាល់ខ្លួនរបស់កម្ពុជា https://data.opendevelopmentcambodia.net/en/dataset/087a5b1e-bc04-4da1-8870-c375b87e01f2/resource/fd8b0cb3-afc4-44d0-a9c8-1e482a9f7e2c/download/icnl-comments-on-cambodia-draft-law-on-personal-data-protection_july2025.pdf

**មាត្រា ៤**

មាត្រា ៤ នៃសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារទិន្នន័យបុគ្គលកំណត់ថា ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ត្រូវដើរតួជាការិយាល័យត្រួតពិនិត្យការអនុវត្តច្បាប់ និងបញ្ញត្តិច្បាប់។ ការកំណត់នេះគឺជាឧត្តមានុវត្ត អន្តរជាតិដែលស្ថាប័នដែលត្រួតពិនិត្យការការពារទិន្នន័យមានភាពឯករាជ្យ និងស្វ័យភាពគ្រប់គ្រាន់ ដែលរួមមានបញ្ញត្តិផ្សេងៗ ដូចជារយៈពេលកំណត់សម្រាប់អ្នកត្រួតពិនិត្យទិន្នន័យ ការដកតំណែងអ្នកត្រួតពិនិត្យលុះត្រាតែមានមូលហេតុត្រឹមត្រូវ និងថវិកាកំណត់ដែលអ្នកត្រួតពិនិត្យមានការគ្រប់គ្រងពេញលេញ។ កង្វះឯករាជ្យភាពនៅក្នុងគណៈកម្មាការទិន្នន័យ ឬស្ថាប័នត្រួតពិនិត្យណាមួយមានហានិភ័យដែលបញ្ហាការពារទិន្នន័យ និង/ ឬស្ថាប័នត្រួតពិនិត្យនឹងត្រូវបានប្រើប្រាស់ជាអាវុធនយោបាយ។ កង្វល់នេះត្រូវបានបង្ហាញជាពិសេស បើពិចារណាលើកង្វល់ដែលមានស្រាប់ពាក់ព័ន្ធនឹងកង្វះភាពជាក់លាក់ នៅក្នុងការរៀបចំពាក្យពេចន៍មួយចំនួនក្នុងមាត្រាផ្សេងទៀតនៃសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារទិន្នន័យបុគ្គលដូចដែលបានលើកឡើងខាងលើ។

# សេចក្ដីសន្និដ្ឋាន

ការវិភាគផ្លូវច្បាប់នេះមានគោលបំណងបង្ហាញពីរបៀបដែលបញ្ញត្តិច្បាប់ជាធរមានបានបង្កើតបរិយាកាស មួយដែលការអនុវត្តសិទ្ធិសេរីភាពខាងការបញ្ចេញមតិលើអនឡាញមានការរឹតត្បិតខ្លាំងរួចជាស្រេច ហើយផ្នែកមួយចំនួននៃសេចក្ដីព្រាងច្បាប់ប្រឈមនឹងការរឹតត្បិតសិទ្ធិនេះថែមទៀត។ នៅក្នុងឧទាហរណ៍គួរដែលជាកង្វល់ ដូចជាសេចក្ដីព្រាងច្បាប់ស្ដីពីបទល្មើសបច្ចេកវិទ្យា បទល្មើស "បរិហារកេរ្តិ៍" មិនត្រឹមតែកំណត់ទោសទណ្ឌមិនសមាមាត្រប៉ុណ្ណោះទេ ប៉ុន្តែទោសទណ្ឌបែបនេះធ្វើឱ្យកាន់តែមានភាពធ្ងន់ធ្ងរបើប្រៀបធៀបទៅនឹងច្បាប់ជាធរមាន។ កត្តានេះបណ្ដាលឱ្យមានក្តី កខ្វល់ខ្លាំង ដោយសារបទល្មើស បរិហារកេរ្តិ៍ (មាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ) ត្រូវបានយក មកអនុវត្តជាញឹកញាប់ តាមអំពើចិត្តប្រឆាំងនឹងតួអង្គសង្គមស៊ីវិល ដូចជា អ្នកការពារសិទ្ធិមនុស្ស អ្នកសារព័ត៌មាន សកម្មជននយោបាយ និងថែមទាំង អ្នកប្រើបណ្ដាញទំនាក់ទំនងសង្គមដោយសារពួកគេ បញ្ចេញទស្សនៈផ្ទាល់ខ្លួនអំពីឥស្សរជនក្នុងថ្នាក់ដឹកនាំនយោបាយ ឬអ្នកជំនួញដែលមានឥទ្ធិពល។

ដូចដែលការវិភាគផ្លូវច្បាប់នេះបានបង្ហាញ លក្ខណៈរួមនៅក្នុងសេចក្ដីព្រាងច្បាប់ទាំងនេះមានកង្វះខាត ភាពជាក់លាក់ក្នុងការរៀបចំពាក្យពេចន៍បញ្ញត្តិច្បាប់ ដែលបណ្ដាលឱ្យមានក្ដីកង្វល់ថាសេចក្ដីព្រាងច្បាប់ទាំងនេះអាចត្រូវបានអនុវត្តដោយមិនស្របតាមគោលបំណង ដែលបានបញ្ជាក់ក្នុងសេចក្ដីព្រាងច្បាប់ទាំងនេះ។ ម.ស.ម.ក អំពាវនាវឱ្យរាជរដ្ឋាភិបាលកម្ពុជាធ្វើការពិគ្រោះប្រកបដោយអត្ថន័យជាមួយអ្នកជំនាញ និងអង្គការសិទ្ធិមនុស្សដែលមានជំនាញអំពីសិទ្ធិសេរីភាពខាងការបញ្ចេញមតិ សិទ្ធិទទួលព័ត៌មាន និងការការពារទិន្នន័យ ដើម្បីធានាបាននូវការប្រើពាក្យពេចន៍ជាក់លាក់នៅក្នុងសេចក្ដីព្រាងច្បាប់ទាំងនេះ ដើម្បីឱ្យប្រជាពលរដ្ឋកម្ពុជាយល់ ហើយធ្វើសកម្មភាពស្របតាមច្បាប់។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ការចូលរួមត្រូវតែលើសពីការពិគ្រោះយោបល់ ហើយត្រូវដាក់បញ្ចូលមតិយោបល់ប្រកបដោយអត្ថន័យ និងស្មារតីសុចរិត។

សេចក្ដីព្រាងច្បាប់ដែលបានបញ្ជាក់ក្នុងការវិភាគនេះក្នុងទម្រង់បច្ចុប្បន្ន តម្រូវឱ្យមានការកែសម្រួល សំខាន់ៗ ដើម្បីធានាថា សេចក្ដីព្រាងច្បាប់អនុលោមតាមកាតព្វកិច្ចរបស់កម្ពុជាក្រោមច្បាប់ស្ដីពីសិទ្ធិមនុស្សអន្តរជាតិ។ ដូច្នេះ ម.ស.ម.ក អំពាវនាវឱ្យរាជរដ្ឋាភិបាលកម្ពុជា ចូលរួមក្នុងន័យស្ថាបនាជាមួយបុគ្គល និងអង្គការនានាដែលអាចជានាបាននូវអនុលោមភាពនេះ ហើយធ្វើវិសោធនកម្មលើសេចក្ដីព្រាងបច្ចុប្បន្ន ដើម្បីផលប្រយោជន៍របស់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ ព្រមទាំងគោរពសិទ្ធិសេរីភាពរបស់ពួកគាត់នៅក្នុងការបញ្ចេញមតិផងដែរ។

# អនុសាសន៍ជូនរាជរដ្ឋាភិបាលកម្ពុជា៖

- ពិចារណាធ្វើវិសោធនកម្ម ឬកែសម្រួលមាត្រា ៣០៥, ៤៩៤, ៤៩៥, ៣០៧, ៥២៣ និង ៥០២ នៃក្រមព្រហ្មទណ្ឌ ជាផ្នែកមួយនៃដំណើរការដើម្បីកែសម្រួលក្រមនេះ ដើម្បីធានាថា សិទ្ធិសេរីភាពខាងការបញ្ចេញមតិត្រូវបានច្បាប់ការពារយ៉ាងពេញលេញ និងមានចែងនៅក្នុងច្បាប់។
- ពិចារណាធ្វើវិសោធនកម្មមាត្រា ១១, ១២, ១៣ និង ១៤ នៃច្បាប់ស្តីពីរបបសារព័ត៌មាន ដើម្បីធានាថាការរឹតត្បិតខ្លឹមសារគឺមិនរឹតត្បិតហួសហេតុនូវសិទ្ធិសេរីភាពខាងការបញ្ចេញមតិ។
- ពាក់ព័ន្ធនឹងច្បាប់ស្តីពីទូរគមនាគមន៍ (២០១៥) និងប្រកាសអន្តរក្រសួងលេខ ១៧០ ស្តីពីការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម (២០១៨)៖
    - ពិចារណាក្នុងការកែសម្រួលមាត្រា ៦៦ និង ៧ នៃច្បាប់ស្តីពីទូរគមនាគមន៍ ដើម្បីធានាបាននូវភាពជាក់លាក់ និងភាពច្បាស់លាស់ល្អប្រសើរជាងមុននៅក្នុងការរៀបចំពាក្យពេចន៍ក្នុងច្បាប់នេះ រួមមានទាហរណ៍ជាក់លាក់ ដូច្នេះហើយភាពច្បាស់លាស់ផ្លូវច្បាប់ស្របតាមគោលការណ៍ច្បាប់នៅក្នុងលក្ខណៈវិនិច្ឆ័យដែលមានបីផ្នែកនៅក្នុងច្បាប់អន្តរជាតិ។
    - ពិចារណាលើការកែសម្រួលប្រការ ២, ៦, ៧ និង ៨ នៃប្រកាសអន្តរក្រសួងដើម្បីធានាថា ប្រការទាំងនេះមានភាពជាក់លាក់ និងច្បាស់លាស់គ្រប់គ្រាន់នៅក្នុងការរៀបចំពាក្យពេចន៍ ដូច្នេះអនុញ្ញាតឱ្យបុគ្គលនានាធ្វើសកម្មភាពស្របទៅតាមនោះ។
- ពិចារណាលើការកែសម្រួលសំខាន់ៗ ឬលុបចោលធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន ដើម្បីធានាថា ធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មានជួយសម្រួលជាជាងរឹតត្បិតសេរីភាពសារព័ត៌មាន។
- ពិចារណាលើការកែសម្រួលសំខាន់ៗ ឬលុបចោលអនុក្រឹត្យស្តីពីច្រកទ្វារអ៊ីនធឺណិតជាតិ ដោយសារអំណាចច្រើនដែលអនុក្រឹត្យនេះផ្តល់ឱ្យសម្រាប់ការតាមដាន ការឃ្លាំមើល ការស្ទាក់ចាប់ និងការត្រួតពិនិត្យសកម្មភាពលើអនឡាញដែលអាចជាការហួសពីសិទ្ធិអំណាចរបស់រដ្ឋាភិបាល។
- ពិចារណាលើការកែសម្រួលមាត្រា ៥, ៧, ៤២, ៤៣, ៤៤ និង ៤៩ នៃសេចក្តីព្រាងច្បាប់ស្តីពីបទល្មើស
- បច្ចេកវិទ្យា ជាពិសេសការលុបចោលការដាក់ពន្ធនាគារជាទោសតាមមាត្រា ៤២ និង ៤៣ ដើម្បីធានាថាច្បាប់ស្របតាមក្រមព្រហ្មទណ្ឌកម្ពុជា។
- ពិចារណាលើការកែសម្រួលមាត្រា ៤, ២០, ២៦ និង ៣៣ នៃសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានដើម្បីធានាថាច្បាប់នេះអនុញ្ញាតឱ្យមានការអនុវត្តប្រកបដោយអត្ថន័យនូវសិទ្ធិទទួលព័ត៌មានដោយគ្មានការរឹតត្បិតហួសហេតុ និងទូលំទូលាយពេក។
- ពិចារណាលើការកែសម្រួលមាត្រា ៤, ២១, ២៦, និង ២៧ ដើម្បីធានាថា សិទ្ធិអំណាចដែលផ្តល់ជូនគណៈកម្មាធិការសន្តិសុខឌីជីថល (គ.ស.ឌ.) គឺសមាមាត្រទៅនឹងគោលបំណងដែលបានបញ្ជាក់ក្នុងច្បាប់ និងអនុលោមតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងតម្រូវការសម្រាប់ការរឹតត្បិតរីភាពខាងការបញ្ចេញមតិដែលជា "វិធានការមានការរំខានតិចតួចបំផុត" ។
- ពិចារណាលើការកែសម្រួលមាត្រា ៤, ៧ និង ១៤ នៃសេចក្តីព្រាងច្បាប់ស្តីពីការការពារទិន្នន័យបុគ្គលដើម្បីធានាថា ច្បាប់នេះស្របតាមឧត្តមានុវត្តអន្តរជាតិពាក់ព័ន្ធនឹងច្បាប់ស្តីពីកិច្ចការពារទិន្នន័យ។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights